ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# គោលការណ៍ណែនាំថ្នាក់ជាតិ
# ស្តីពី
# សុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាព

ឆ្នាំ ២០១៦

# អារម្ភកថា

សៀវភៅនេះគឺជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្ត្ររបស់កម្មវិធីជាតិសុខភាពបន្តពូជ ក្នុងការបញ្ចូលសុខភាពបន្តពូជយុវវ័យទៅក្នុងផែនការយុទ្ធសាស្ត្រជាតិ។ នៅក្នុងប្រទេសកម្ពុជា ក្រុមយុវវ័យដែលមានអាយុពី១០ទៅ២៤ឆ្នាំ កំពុងឆ្លងកាត់នូវដំណាក់កាលមួយ ដែលប្រកបដោយគ្រោះថ្នាក់និយាយរួម គឺពួកគេកំពុងតែប្រឈមមុខនឹងបញ្ហាផ្សេងៗដូចជាៈ បញ្ហាទំនាក់ទំនងជាដៃគូក្នុងរឿងភេទ ការមានផ្ទៃពោះដែលមិនចង់បាន ការរំលូតកូនគ្មានសុវត្ថិភាព ជំងឺកាមរោគ/អេដស៍វិសមភាពនៃយេនឌ័រ ការប្រើប្រាស់គ្រឿងញៀន អំពើហិង្សា និង ងាយរងគ្រោះធ្លាក់ក្នុងអាជីវកម្មផ្លូវភេទ។ល។

ក្រុមយុវវ័យនៅគ្រប់ទីកន្លែងភាគច្រើន មានការលំបាកក្នុងការទទួលយកព័ត៌មានសេវាកម្មសុខភាពបន្ត ពូជនិងសុខភាពផ្លូវភេទ។ ទោះបីជាស្ថិតនៅក្នុងស្ថានភាពនេះក៏ដោយ ក៏ក្រុមយុវវ័យមួយចំនួនបានរៀនពីបទដ្ឋាននៃការប្រព្រឹត្តក្នុងការការពារខ្លួនរបស់ពួកគេតាមរយៈឪពុកម្តាយ មិត្តភ័ក្តិនៅសាលារៀននិងក្លឹបកីឡា ការអប់រំសាសនា និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ប៉ុន្តែចំណេះដឹងទាំងនេះ នៅមិនទាន់គ្រប់គ្រាន់សម្រាប់ពួកគេនៅឡើយទេ។

អាស្រ័យដោយមានកង្វះខាតនូវចំណេះដឹងផ្នែកសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ការស្វែងរកនិងការទទួលយកសេវាកម្មសុខភាព ហើយដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យតាមរយៈការជំរុញឱ្យពួកគេមានឥរិយាបថវិជ្ជមាន ចំពោះការស្វែងរក និងទទួលយកសេវាកម្មសុខភាពបន្តពូជនិងសុខភាពផ្លូវភេទប្រកបដោយសុវត្ថិភាព និងបង្កើននូវការប្រើប្រាស់សេវាកម្មសុខភាពបន្តពូជយុវវ័យនៅសេវាសាធារណៈ ទើបក្រសួងសុខាភិបាលសហការជាមួយអង្គការដៃគូអភិវឌ្ឍន៍ក្រោមការជួយឧបត្ថម្ភថវិការបស់អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) បានផ្តួចផ្តើមធ្វើបច្ចុប្បន្នភាព រៀបចំកែសម្រួលជាថ្មីនូវ"គោលការណ៍ណែនាំថ្នាក់ជាតិស្តីពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាព" នេះឡើង សម្រាប់ពង្រឹងសមត្ថភាពផ្នែកបច្ចេកទេសដល់បុគ្គលិកសុខាភិបាល ក្នុងការផ្តល់សេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទឱ្យដល់យុវវ័យប្រកបដោយមិត្តភាពនិងប្រសិទ្ធភាពខ្ពស់។

ភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងសុខាភិបាល

សាស្ត្រាចារ្យ អេង_ហួត
រដ្ឋលេខាធិការ

# សេចក្តីថ្លែងអំណរគុណ

ពិធីសារជាតិស្តីពីសុខភាពបន្តពូជយុវវ័យជាលទ្ធផលនៃកិច្ចប្រឹងប្រែងរៀបចំពិនិត្យ និងកែសម្រួលដោយក្រុមការងារបច្ចេកទេសសុខភាពបន្តពូជដែលជាមន្ត្រីសុខាភិបាលនៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក និងអង្គការដៃគូអភិវឌ្ឍន៍សុខាភិបាលនានា។

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រីទាំងអស់ ជាមន្ត្រីកម្មវិធីជាតិសុខភាពបន្តពូជនៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក ព្រមទាំងមន្ត្រីនានារបស់អង្គការ UNFPA, WHO, USAID, RHAC, RACHA, MSIC, PSK និង FHI360 ដែលបានចំណាយពេលវេលា និងចូលរួមផ្តល់យោបល់ក្នុងដំណើរធ្វើបច្ចុប្បន្នភាព រៀបចំកែសម្រួលជាថ្មីនូវ "គោលការណ៍ណែនាំថ្នាក់ជាតិស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាព" នេះ។

សូមថ្លែងអំណរគុណជាពិសេសចំពោះ មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ដែលបានជួយឧបត្ថម្ភថវិកាគាំទ្រដល់ការរៀបចំ ពិនិត្យឡើងវិញព្រមទាំងការបោះពុម្ពពិធីសារជាតិស្តីពីសុខភាពបន្តពូជយុវវ័យ។

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៦

# មាតិកា

គោលការណ៍ណែនាំថ្នាក់ជាតិ
ស្តីពី
សុខភាពបន្តពូជ
និងសុខភាពផ្លូវភេទ
យុវវ័យប្រកបដោយមិត្តភាព


អារម្ភកថា ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

១. សេចក្តីផ្តើម ........ ១

២. ស្ថានភាពយុវវ័យបច្ចុប្បន្ន ........ ២

៣. គោលនយោបាយ ........ ៤

៤. ស្តង់ដារកម្រិតសកលលោកសម្រាប់សេវាគាំទ្រយុវវ័យប្រកបដោយគុណភាព ........ ៨

៥. សុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាព ........ ១០

៦. គុណភាពសេវាសុខភាពយុវវ័យប្រកបដោយមិត្តភាព ........ ១៤

៧. លក្ខខណ្ឌក្នុងការបង្កើតឱ្យមានសេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទសម្រាប់យុវវ័យ ........ ១៦

៨. ការគាំទ្រនៅមូលដ្ឋាន ........ ១៩

៩. អភិបាលគាំទ្រ ការពិនិត្យតាមដាន និង វាយតម្លៃ ........ ២៣

១០. ការស្រាវជ្រាវ ........ ៣០

១១. ឧបសម្ព័ន្ធ ........ ៣១

១២. ឧបសម្ព័ន្ធសម្រាប់គ្រូបណ្តុះបណ្តាល ........ ៤៥

# ១. សេចក្តីផ្តើម

យុវវ័យជាដំណាក់កាលមួយនៃជីវិតក្នុងអំឡុងពេលដែលរូបរាងកាយវិវឌ្ឍនពីកុមារភាព ទៅភាពពេញកម្លោះក្រមុំ។ សុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យបានបង្ហាញឱ្យឃើញនូវបញ្ហាពាក់ពន្ធ័នឹងកង្វល់យ៉ាងច្រើនដល់ប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ហើយវានៅតែជាបញ្ហាចំបងក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ជាពិសេសនៅប្រទេសកម្ពុជា ទោះបីជាមានភាពប្រសើរឡើងនៅឆ្នាំថ្មីៗនេះក៏ដោយ។

យុវវ័យត្រូវបានធានាឱ្យមានសុខភាពផ្លូវកាយ ផ្លូវចិត្តនិងសង្គម មានឱកាសសម្រាប់ជីវិតរស់នៅល្អប្រសើរ និងគេចផុតពីការរំលោភបំពានផ្លូវភេទ។ ពួកគេមានសិទ្ធិចូលរួមក្នុងការសម្រេចចិត្តនិងធ្វើ សកម្មភាពដែលមានឥទ្ធិពលលើជីវិតរបស់ពួកគេ។

នៅកម្ពុជា សេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាពទាមទារឱ្យមានការចូលរួមរបស់យុវវ័យក្នុងសកម្មភាពលើកកម្ពស់សុខភាពយុវវ័យ។ យុវវ័យ បុរស ស្ត្រីមានតម្រូវការផ្នែកសុខភាពបន្តពូជខុសៗគ្នា ហើយវាមានសារៈសំខាន់ដែលធ្វើឱ្យមានការចូលរួមពីបុរសដើម្បីជំរុញនូវតម្រូវការផ្នែកសុខភាពបន្តពូជនិងសុខភាពផ្លូវភេទផ្ទាល់ខ្លួន ក៏ដូចជាដៃគូររបស់ពួកគេដែរ។

ការចូលរួមរបស់បុរសគឺមិនមែនគ្រាន់តែមានតួនាទីជាក្រុមអតិថិជនបន្ថែមនោះទេ ប៉ុន្តែជាការធ្វើឱ្យប្រសើរឡើងនូវសុខភាពស្ត្រីតាមរយៈការអប់រំអំពីតម្រូវការរបស់ដៃគូបុរស។ អត្ថប្រយោជន៍ផ្សេងទៀតនៃការផ្តល់សេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យ អាចជះឥទ្ធិពលផ្សេងទៀតនៃការ ផ្តល់សេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យអាចជះឥទ្ធិពលជាប្រយោលក្នុងរយៈពេលវែងនៃការចូលរួមរបស់បុរសទូទៅក្នុងសុខភាពបន្តពូជដូចដែលយុវវ័យក្នុងគ្រួសារអាចជាគំរូនៃការផ្លាស់ប្តូរអាកប្បកិរិយាឆ្ពោះទៅរកសមធម៌យេនឌ័រ ផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រនិងការប្រព្រឹត្តដោយគ្រោះថ្នាក់ខ្ពស់។

គោលការណែនាំនេះមានការគាំទ្រពីក្រសួងសុខាភិបាលនៅកម្ពុជា។កម្មវិធីជាតិ សុខភាពបន្តពូជបានឈរលើឧត្តមភាពការងាររបស់បុគ្គលិក អង្គការជាតិ អន្តរជាតិដែល បានធ្វើការស្រាវជ្រាវឬបានធ្វើការជាមួយយុវវ័យ ដើម្បីបំពេញសេចក្តីត្រូវការនៃសេវានិងព័ត៌មានមានសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យ។ គោលការណែនាំស្តង់ដារបន្តបន្ទាប់នេះកម្មវិធីសុខភាពបន្តពូជបានកំណត់នូវស្តង់ដារ១០ចំណុច តាមរយៈសេវាយុវវ័យប្រកបដោយមិត្តភាពនៅមូលដ្ឋានសុខាភិបាលដែលត្រូវបានពិនិត្យតាមដាននិងវាយតម្លៃ។ ស្តង់ដារទាំងនោះផ្អែកលើការថែទាំអតិថិជនបានល្អហើយត្រូវបានកំណត់ដោយយុវវ័យផ្ទាល់ខ្លួនរបស់គេតាមរយៈការធ្វើសន្និសិទ និងការពិភាក្សាជាក្រុមនៅកម្ពុជាហើយវានឹងត្រូវអនុវត្តដោយមានការលំបាកជាច្រើនជាមួយ នឹងបញ្ហានៃហិរញ្ញវត្ថុ និងធនធានរបស់កម្មវិធីជាតិសុខភាពបន្តពូជ។

# ២. ស្ថានភាពយុវវ័យបច្ចុប្បន្ន

## យុវវ័យនិងសុខភាពបន្តពូជ-សុខភាពផ្លូវភេទនៅលើពិភពលោក

រៀងរាល់ឆ្នាំ ក្នុងពិភពលោក មានយុវវ័យប្រមាណ១៦លាននាក់ដែលមានអាយុពី១៥-១៩បានក្លាយជាម្តាយរបស់គេ។ យុវវ័យដែលមានផ្ទៃពោះនៅវ័យក្មេងភាគច្រើនជាអ្នកក្រីក្រមានការអប់រំតិចតួចហើយរស់នៅក្នុងតំបន់ជនបទ។ ទោះបីជាមានការរីកចំរើនប៉ុន្តែចំនួនយុវវ័យដែលមានផ្ទៃពោះនៅតែបន្តកើនឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលក្នុងនោះជារៀងរាល់ថ្ងៃមានយុវវ័យអាយុក្រោម១៨ឆ្នាំប្រមាណ២០,០០០នាក់បានផ្តល់កំណើតកូន។ នៅពេលមានផ្ទៃពោះវ័យក្មេងជីវិតរបស់នាងមានការផ្លាស់ប្តូរទាំងស្រុងការសិក្សាអាចនឹងត្រូវបានបញ្ចប់ ហើយអនាគតការងារអាចនឹងបាត់បង់។ នាងងាយនឹងរងគ្រោះដោយសារភាពក្រីក្រត្រូវបានសង្គមរើសអើងនិងសុខភាពមានការថយចុះ។ ផលវិបាកជុំវិញការមានផ្ទៃពោះ និងការសម្រាលជាមូលហេតុចំបងនៃមរណភាពនៅក្នុង ចំណោមស្ត្រីវ័យក្មេង។ ភាគច្រើនការមានផ្ទៃពោះនៅវ័យក្មេងមិនមែនជាជម្រើសរបស់នាងទេបញ្ហា នេះបណ្តាលមកពីនាងមិនបានទទួលការអប់រំទទួលព័ត៌មាននិងសេវាសុខភាព។

បច្ចុប្បន្ន ដោយសារតែយុវវ័យជាច្រើនឆាប់ពេញវ័យបានធ្វើឱ្យពួកគេប្រឈមមុខនឹងការរួមភេទមុនពេលរៀបការជាហេតុធ្វើឱ្យងាយនឹងមានបញ្ហាសុខភាពបន្តពូជ រួមមានការមានផ្ទៃពោះ ការរំលូតកូនគ្មានសុវត្ថិភាព ការឆ្លងជំងឺកាមរោគ-មេរោគអេដស៍ និងទទួលរងនូវការបំពានផ្លូវភេទ។ ភាគច្រើនយុវវ័យដែលសកម្មក្នុងការរួមភេទ មិនបានទទួលសេវាសុខភាពបន្តពូជ ដូចជាការពន្យារកំណើត ការព្យាបាលជំងឺកាមរោគអេដស៍ឬបើបានទទួលសេវាក៏ទទួលទាំងអារម្មណ៍មិនស្វាគមន៍ហើយធ្វើឱ្យយុវវ័យមានការខ្មាស់អៀន។

## យុវវ័យនិងសុខភាពបន្តពូជសុខភាពផ្លូវភេទនៅកម្ពុជា

យោងតាមការអង្កេតជំរឿនប្រជាជនកម្ពុជាឆ្នាំ២០០៨ បង្ហាញឱ្យឃើញថា ក្រុមអាយុ១០ទៅ២៤ឆ្នាំ មាន៣២% នៃចំនួនប្រជាជនកម្ពុជាសរុប ដែលស្មើនឹង៤,៥លាននាក់។

យោងតាមការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០១៤ អត្រាមរណភាពមាតាមានចំនួន១៧០នាក់ក្នុងចំណោម១០០.០០០កំណើតរស់ដែលចំនួននេះនៅតែខ្ពស់ ចំណែកឯអត្រាមានកូននៅវ័យក្មេងមាន៨%នៅក្នុងឆ្នាំ២០១០ហើយអត្រានេះបានកើនឡើងដល់១២% នៅឆ្នាំ២០១៤ ក្នុងនោះយុវវ័យ ដែលមានអាយុពី១៥-១៩ឆ្នាំមានចំនួន១នាក់ក្នុងចំណោម៨នាក់បានក្លាយជាមាតា ឬកំពុងមានផ្ទៃពោះកូនដំបូង។ ស្ត្រីវ័យក្មេងដែលចាប់ផ្តើមមានផ្ទៃពោះកូនដំបូងបានកើនឡើងពី

ក្រោម១%ក្នុងចំណោមស្ត្រីវ័យក្មេងអាយុ១៥ឆ្នាំទៅដល់៣១% ក្នុងចំណោមស្ត្រីវ័យក្មេងអាយុ១៩ឆ្នាំ។ ៦%នៃស្ត្រីវ័យក្មេងរស់នៅទីក្រុងនិង១៣%នៃស្ត្រីវ័យក្មេងរស់នៅតាមជនបទមានកូនដំបូងមុនអាយុ២០ឆ្នាំ។ អត្រានៃការមានផ្ទៃពោះនៅវ័យក្មេងមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងកម្រិតនៃការសិក្សា ក្នុងនោះស្ត្រីវ័យក្មេងដែលមិនបានចូលសាលាចាប់ផ្តើមមានកូនដំបូងមាន៣៧%បានទទួលការសិក្សាកម្រិតបឋមមាន១៨% និងបានទទួលការសិក្សាកម្រិតមធ្យមមានចំនួនតិចជាង១០%។

## ការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបក្នុងចំណោមស្ត្រីវ័យក្មេងអាយុពី១៥-១៩ឆ្នាំដែលបានរៀបការមានចំនួន២០% ហើយមធ្យោបាយថ្នាំគ្រាប់ត្រូវបានប្រើប្រាស់ច្រើនជាងគេ។

ក្រសួងអប់រំយុវជននិងកីឡា បានបង្កើតគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានៅឆ្នាំ២០១១។ ទន្ទឹមនឹងនេះសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យជាអាទិភាពចំបងមួយរបស់ផែនការយុទ្ធសាស្ត្រជាតិសុខាភិបាលនៃក្រសួងសុខាភិបាល។ ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រជាតិសុខាភិបាលកម្មវិធីជាតិសុខភាពបន្តពូជ ក៏បានបង្កើតផែនការយុទ្ធសាស្ត្រជាតិគោលការណ៍ណែនាំនិងពិធីសារជាតិស្តីអំពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យ។

ទោះជាយ៉ាងនេះក្តី រចនាសម្ព័ន្ធការផ្តល់សេវាចំណេះដឹងនិងជំនាញរបស់អ្នកផ្តល់សេវានិងការផ្សព្វផ្សាយអប់រំពីសុខភាពរបស់យុវវ័យនៅមានកម្រិត ជាហេតុធ្វើឱ្យយុវវ័យជាច្រើននៅតែមានការខ្វះខាតនូវព័ត៌មានអំពីសុខភាពបន្តពូជជាមូលដ្ឋាន និងការទទួលបាននូវសេវាប្រកបដោយគុណភាព។មានកត្តាជាច្រើនទៀតដែលរារាំងមិនឱ្យយុវវ័យស្វែងរកការថែទាំនិងព្យាបាលត្រឹមត្រូវឱ្យបានទាន់ពេលវេលាគឺពាក់ព័ន្ធទៅនឹងភាពជាឯកជន និងលទ្ធភាពនៃការបង់ថ្លៃសេវាឬការមិនពេញចិត្តអ្នកផ្តល់សេវា។យុវវ័យជាច្រើនមានការខ្មាស់អៀនមិនហ៊ានពិភាក្សាជាមួយឪពុកម្តាយឬយុវវ័យដទៃទៀតអំពីការរួមភេទឬសុខភាពបន្តពូជ។

កម្មវិធីជាតិសុខភាពបន្តពូជជឿជាក់ថាការបំពេញតម្រូវការព័ត៌មាន និងការផ្តល់សេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទសម្រាប់យុវវ័យ អាចនឹងធ្វើឱ្យសុខភាពយុវវ័យមានភាពប្រសើរឡើង។ សេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទសម្រាប់យុវវ័យ ត្រូវបានបញ្ចូលទៅក្នុងសេវាសុខភាពដែលមានស្រាប់។

# ៣. គោលនយោបាយ

## គោលនយោបាយជាតិទាក់ទងនឹងសុខភាពបន្តពូជនិងសុខភាពផ្លូវភេទសម្រាប់យុវវ័យប្រកបដោយមិត្តភាពនិងការឆ្លើយតបរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ទៅលើផ្នែកសុខភាពជាចំបង ដែលនៅក្នុងនោះ សុខភាពបន្តពូជយុវវ័យ នៅតែជាការទទួលខុសត្រូវរបស់គោលនយោបាយដទៃទៀត ដូចជាគោលនយោបាយសុខភាពមាតានិងទារកគោលនយោបាយពន្យារកំណើតគោលនយោបាយសមភាពសមធម៌និងយេនឌ័រ។

ច្បាប់គោលនយោបាយគោលការណ៍ណែនាំនិងផែនការយុទ្ធសាស្ត្រនានាដែលមានស្រាប់បានគាំទ្រដល់ការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីអំពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ៖

| | |
|---|---|
| – គោលនយោបាយជាតិស្តីពីការពន្យារកំណើត | ១៩៩៥ |
| – ច្បាប់រំលូតកូន | ១៩៩៧ |
| – គោលនយោបាយនិងយុទ្ធសាស្ត្រជាតិស្តីពីមាតុភាពគ្មានគ្រោះថ្នាក់ | ១៩៩៧ |
| – គោលនយោបាយជាតិស្តីពីការការពារការឆ្លងរោគពីម្តាយទៅកូន | ២០០១ |
| – ប្រកាសស្តីពីការណែនាំអនុវត្តច្បាប់រំលូតកូន | ២០០២ |
| – គោលនយោបាយអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្តនិងផ្តល់ប្រឹក្សាដោយរក្សាការសម្ងាត់ | ២០០២ |
| – គោលដៅអភិវឌ្ឍន៍សហសវត្ស | ២០០៥-២០១៥ |
| – គោលការណ៍ណែនាំសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ របស់យុវវ័យ | ២០០៨ |
| – ផែនការយុទ្ធសាស្ត្រជាតិសម្រាប់វិស័យសុខាភិបាល | ២០០៨-២០១៥ |
| – ផែនការយុទ្ធសាស្ត្រជាតិពហុវិស័យសម្រាប់ការឆ្លើយតបទៅនឹង មេរោគអេដស៍/ជំងឺអេដស៍ | ២០១១-២០១៥ |
| – គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា | ២០១១ |
| – គោលនយោបាយនិងគោលការណ៍ណែនាំជាតិសម្រាប់ ការផ្តល់បន្ថែមមីក្រូសារជាតិដើម្បីការពារនិងទប់ស្កាត់បញ្ហា កង្វះមីក្រូសារជាតិនៅប្រទេសកម្ពុជា | ២០១២ |
| – ផែនការយុទ្ធសាស្ត្រជាតិសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ | ២០១៣-២០១៦ |
| – គោលនយោបាយជាតិប្រជាជន | ២០១៦-២០៣០ |
| – ផែនទីចង្អុលផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាស្លាប់របស់មាតា និងទារក | ២០១៦-២០២០ |

កន្លងមកនេះបណ្ដាក្រសួងទាំងឡាយនៃប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងបង្កើតនិងអនុវត្តនូវច្បាប់គោលនយោបាយ គោលការណ៍ណែនាំផែនការយុទ្ធសាស្ត្រនិងកម្មវិធីសិក្សាដែលបានយកចិត្តទុកដាក់ខ្ពស់លើសុខភាពយុវវ័យ ៖

- ក្រសួងសុខាភិបាលមានគោលការណ៍ណែនាំស្តង់ដារថ្នាក់ជាតិសម្រាប់សេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យប្រកបដោយមិត្តភាពដែលជាផ្នែកមួយនៅក្នុងយុទ្ធសាស្ត្រជាតិសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ២០១៣-២០១៦។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានផែនការយុទ្ធសាស្ត្រជាតិពហុវិស័យសម្រាប់ការឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍២០១១-២០១៥និងច្បាប់ការពារប្រយុទ្ធនឹងជំងឺអេដស៍ហើយបច្ចុប្បន្នកំពុងបង្កើតឱ្យមានផែនការយុទ្ធសាស្ត្រ២០១៦-២០២០ដែលក្នុងនោះយុវវ័យត្រូវបានចាត់ទុកជាអាទិភាពផងដែរក្នុងចំណោមអាទិភាពដទៃទៀត។
- ក្រសួងអប់រំយុវជននិងកីឡាកំពុងអនុវត្តកម្មវិធីសិក្សាបំណិនជីវិតស្តីអំពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យថ្នាក់សិក្សាទី៥ទី៦ទី៧ទី៨ទី១០និងទី១១។
- ក្រសួងកិច្ចការនារីបានបន្តកិច្ចសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍តាមរយៈការគាំទ្រ " គោលនយោបាយអំពីស្ត្រីក្មេងស្រីនិងមេរោគអេដស៍/ជំងឺអេដស៍ " ហើយបច្ចុប្បន្ននេះក្រសួងក៏បានបង្កើតកម្មវិធីបណ្តុះបណ្តាលស្តីពីការកសាងទំនាក់ទំនងរវាងមាតានិងយុវតីផ្តោតលើយេនឌ័រសុខភាពបន្តពូជនិងសុខភាពផ្លូវភេទឆ្នាំ២០១១។

ដើម្បីលើកកម្ពស់សុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យជាពិសេសកាត់បន្ថយការមានផ្ទៃពោះ ក្នុងចំណោមស្ត្រីវ័យក្មេងអាយុក្រោម១៨ឆ្នាំ កម្មវិធីជាតិសុខភាពបន្តពូជត្រូវអនុវត្តនូវអន្តរាគមន៍សំខាន់ៗទាំង៦ ដោយផ្អែកលើអនុសាសន៍របស់អង្គការសុខភាពពិភពលោកដូចខាងតារាងក្រោម ៖

| អន្តរាគមន៍ | សកម្មភាពកម្រិតថ្នាក់ជាតិ | សកម្មភាពថ្នាក់សហគមន៍គ្រួសារនិងបុគ្គល | សកម្មភាពផ្នែក ប្រព័ន្ធសុខាភិបាល |
|---|---|---|---|
| ទី១. កាត់បន្ថយការរៀបការមុនអាយុ១៨ឆ្នាំ | មិនអនុញ្ញាតិឱ្យរៀបការមុនអាយុ១៨ឆ្នាំ(ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ) | • ផ្សព្វផ្សាយនិងផ្ដល់សិទ្ធិអំណាចដល់ស្ត្រីវ័យ ក្មេង<br>• ជួយស្ត្រីវ័យក្មេងឱ្យបន្តការសិក្សា<br>• ផ្លាស់ប្តូរទំនៀមទម្លាប់ដែលជំរុញឱ្យមានការរៀបការនៅវ័យក្មេង | |
| ទី២. បង្កើន ការយល់ដឹង និង គាំទ្រដើម្បីកាត់បន្ថយការមានផ្ទៃពោះ នៅមុនអាយុ២០ឆ្នាំ | គាំទ្រកម្មវិធីការពារការមានផ្ទៃពោះក្នុងចំណោមយុវវ័យ | • អប់រំយុវវ័យទាំងស្រី ទាំងប្រុសអំពីការរួមភេទប្រកបដោយសុវត្ថិភាព<br>• បង្កើនការគាំទ្រ សហគមន៍អំពីការការពារការមានផ្ទៃពោះនៅវ័យក្មេង | ពិគ្រោះពិភាក្សា ៖<br>• មុនពេលរៀបអាពាហ៍ពិពាហ៍<br>• ផលវិបាកនៃការមានផ្ទៃពោះនៅវ័យក្មេងជាពិសេសក្រុមដែលសកម្មក្នុងការរួមភេទ |
| ទី៣. បង្កើនការប្រើប្រាស់មធ្យោបាយពន្យារកំណើត | • អនុញ្ញាតិឱ្យមានការទទួលព័ត៌មាននិងសេវាពន្យារកំណើត<br>• បន្ធូរបន្ថយតម្លៃសេវាពន្យារកំណើតដល់យុវវ័យ | • អប់រំយុវវ័យពីការប្រើប្រាស់មធ្យោបាយពន្យារកំណើតរួមទាំងការប្រើស្រោមអនាម័យដើម្បីបង្ការការឆ្លងមេរោគអេដស៍និងកាមរោគនិងការមានផ្ទៃពោះដោយមិនបានគ្រោងទុកបង្កើនការគាំទ្រសហគមន៍អំពីការផ្ដល់សេវាពន្យារកំណើតដល់យុវវ័យ<br>• ផ្ដល់លទ្ធភាពដល់យុវវ័យទទួលបាននូវសេវាពន្យារកំណើត | • រៀបចំសេវាសមស្របនិងប្រកបដោយគុណភាពដែលផ្ដល់លទ្ធភាពដល់យុវវ័យអាចទទួលយកបាន<br>• គាំទ្រនិងចូលរួមការអប់រំយុវវ័យ<br>• ការបញ្ជ្រាបសេវាផែនការគ្រួសារនិងមេរោគអេដស៍ |
| ទី៤. កាត់បន្ថយការរួមភេទដោយបង្ខំ | ហាមឃាត់ការរួមភេទដោយបង្ខំ | • ផ្ដល់សិទ្ធិអំណាចដល់ស្ត្រីវ័យក្មេងបដិសេធការរួមភេទដោយបង្ខំ<br>• ផ្លាស់ប្តូរទំនៀមទម្លាប់ដែលជំរុញឱ្យមានការរួមភេទដោយបង្ខំ | • សហការជាមួយក្រសួងពាក់ព័ន្ធក្នុងការរៀបចំនិងអនុវត្តផែនការសកម្មភាពនិងផ្ដល់សារអប់រំរួមទាំងព័ត៌មានពីសេវាគាំទ្រនានា<br>• គាំទ្រចូលរួមពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធ |

| អន្តរាគមន៍ | សកម្មភាពកម្រិតថ្នាក់ជាតិ | សកម្មភាពថ្នាក់សហគមន៍គ្រួសារនិងបុគ្គល | សកម្មភាពផ្នែក ប្រព័ន្ធសុខាភិបាល |
|---|---|---|---|
| | | • ជំរុញឱ្យមានការចូលរួមពីបុរសនិងក្មេងប្រុសដើម្បីវាយតម្លៃស្ថានភាពយេនឌ័រ<br>• គាំទ្រចូលរួមពង្រឹងការអនុវត្តច្បាប់ដែលពាក់ព័ន្ធ | • លើកទឹកចិត្តបុរសនិងក្មេងប្រុសចូលរួមពិគ្រោះពិភាក្សា |
| ទី៥. កាត់បន្ថយការរំលូតកូនគ្មានសុវត្ថិភាព | ផ្តល់លទ្ធភាពដល់យុវវ័យឱ្យទទួលបាននូវសេវារំលូតកូនដោយសុវត្ថិភាពនិងការថែទាំក្រោយរំលូត | • ផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃការរំលូតកូនដោយគ្មានសុវត្ថិភាព<br>• ផ្សព្វផ្សាយអំពីទីកន្លែងដែលយុវវ័យអាចទទួលយកបាននូវសេវារំលូតកូនដោយសុវត្ថិភាពដែលស្របច្បាប់<br>• បង្កើនការយល់ដឹងដល់សហគមន៍អំពីគ្រោះថ្នាក់នៃការរំលូតកូនដោយគ្មានសុវត្ថិភាព | • ពង្រឹងនិងពង្រីកសេវារំលូតកូនដោយសុវត្ថិភាព<br>• កំណត់រកនិងលុបបំបាត់នូវឧបសគ្គក្នុងការទទួលបាននូវសេវារំលូតកូនប្រកបដោយសុវត្ថិភាព<br>• ផ្តល់មធ្យោបាយពន្យារកំណើតក្រោយរំលូត/រលូត |
| ទី៦. បង្កើនការប្រើប្រាស់សេវាពិនិត្យផ្ទៃពោះការសម្រាលនិងការថែទាំក្រោយសម្រាលដោយបុគ្គលិកសុខាភិបាលដែលមានជំនាញនិងសមត្ថភាព | • ពង្រីកការទទួលបាននូវសេវាពិនិត្យផ្ទៃពោះការសម្រាលនិងការថែទាំក្រោយសម្រាលដោយបុគ្គលិក សុខាភិបាលដែលមានជំនាញនិងសមត្ថភាព<br>• ពង្រីកការទទួលបាននូវការថែទាំផ្នែកសម្ភពសង្គ្រោះបន្ទាន់កម្រិតមូលដ្ឋាននិងពេញលេញ | • ផ្សព្វផ្សាយដល់យុវវ័យនិងសមាជិកក្នុងសហគមន៍អំពីសារសំខាន់នៃការថែទាំផ្ទៃពោះការសម្រាលនិងការថែទាំក្រោយសម្រាលដោយបុគ្គលិកសុខាភិបាលដែលមានជំនាញនិងសមត្ថភាព | • ធានាថាយុវវ័យក្រុមគ្រួសារនិងសហគមន៍បានត្រៀមជាស្រេចសម្រាប់ការសម្រាលនិងបញ្ហាសង្គ្រោះបន្ទាន់ជុំវិញការសម្រាល<br>• ពង្រឹងគុណភាពសេវាដែលឆ្លើយតបភ្លាមៗទៅនឹងស្ថានភាពនិងតម្រូវការរបស់ម្តាយនិងស្ត្រីផ្ទៃពោះវ័យក្មេង |

ដើម្បីអនុវត្តនូវអន្តរាគមន៍ខាងលើបានជោគជ័យចាំបាច់ត្រូវបង្កើតឱ្យមានបរិយាកាសវិជ្ជមាននិងគាំទ្រដល់ការអនុវត្តការងារផ្នែកសុខភាពបន្តពូជនិងសុខភាពផ្លូវភេទសម្រាប់យុវវ័យពីស្ថាប័នពាក់ព័ន្ធដូចជារដ្ឋសភា ក្រសួងនានាអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ម្ចាស់ជំនួយសង្គមស៊ីវិលក្រុមយុវវ័យ។ល។

# ៤. ស្តង់ដារកម្រិតសកលលោកសម្រាប់សេវាគាំទ្រយុវវ័យប្រកបដោយគុណភាព

អង្គការសុខភាពពិភពលោកនាពេលថ្មីៗនេះ បានបង្កើតនូវស្តង់ដារជាសកលរួមមួយថ្មីសម្រាប់សេវាប្រកបដោយគុណភាពសម្រាប់យុវវ័យ៖

**ស្តង់ដារទី១:**
យុវវ័យត្រូវតែមានមានចំណេះដឹងគ្រប់គ្រាន់អំពីសុខភាពផ្ទាល់ខ្លួនរបស់ពួកគេ និងដឹងពីមូលដ្ឋានសុខាភិបាលដែលផ្តល់នូវសេវាសុខភាពនិងប្រើប្រាស់សេវាទាំងនោះ។

**ស្តង់ដារទី២:**
ឪពុកម្តាយ អាជ្ញាធរ អាណាព្យាបាល សមាជិកសហគមន៍ដទៃទៀត និងអង្គការសហគមន៍ទទួលស្គាល់នូវតម្លៃនៃការផ្តល់សេវាសុខភាពសម្រាប់យុវវ័យ។ ពួកគាត់គាំទ្រដល់យុវវ័យក្នុងការផ្តល់នូវសេវានិងប្រើប្រាស់សេវាសុខភាពទាំងនោះ។

**ស្តង់ដារទី៣:**
មូលដ្ឋានសុខាភិបាលផ្តល់នូវកញ្ចប់ព័ត៌មានការផ្តល់ប្រឹក្សាធ្វើរោគវិនិច្ឆ័យព្យាបាលនិងថែទាំ ដែលបំពេញនូវតម្រូវការទាំងអស់របស់យុវវ័យ។សេវាទាំងនេះត្រូវបានផ្តល់នៅក្នុងមូលដ្ឋានសុខាភិបាលតាមរយៈការបញ្ជូន និងការចុះមូលដ្ឋាន។

**ស្តង់ដារទី៤:**
អ្នកផ្តល់សេវាសុខភាពត្រូវបង្ហាញសមត្ថភាពបច្ចេកទេសដែលតម្រូវឱ្យមាន ដើម្បីផ្តល់នូវសេវាសុខភាពប្រកបដោយប្រសិទ្ធភាពដល់យុវវ័យ។ ទាំងអ្នកផ្តល់សេវាសុខភាព និងបុគ្គលិកគាំទ្រ ត្រូវគោរព ការពារ និង ផ្តល់នូវសិទ្ធិទទួលបានព័ត៌មាន ភាពជាឯកជន ការលាក់ការសម្ងាត់ និងអាកប្បកិរិយាល្អមិនវិនិច្ឆ័យទៅកាន់យុវវ័យ

**ស្តង់ដារទី៥:**
មូលដ្ឋានសុខាភិបាលត្រូវមានកាលវិភាគផ្តល់សេវាដែលមានភាពងាយស្រួល ទីតាំងផ្តល់សេវាមានអនាម័យ ស្វាគមន៍ រក្សាព័ត៌មានផ្ទាល់ខ្លួន និងការសម្ងាត់។ ត្រូវបំពាក់ឧបករណ៍ សម្ភារៈ ឱសថ និងបច្ចេកទេស វេជ្ជសាស្ត្រតាមកម្រិតមូលដ្ឋានសុខាភិបាលដែលត្រូវការដើម្បីធានាឱ្យបាននូវការផ្តល់សេវាដែលមានប្រសិទ្ធភាពដល់យុវវ័យ។

**ស្តង់ដារទី៦:**

មូលដ្ឋានសុខាភិបាលផ្តល់នូវសេវាគុណភាពដល់យុវវ័យទាំងអស់ ដោយមិនគិតពីសមត្ថភាពក្នុងការបង់ថ្លៃសេវា អាយុ ភេទ ស្ថានភាព គ្រួសារការសិក្សា ជាតិកំណើត ការកំណត់អត្តសញ្ញាណភេទឬលក្ខណសម្បត្តិដទៃទៀត។

**ស្តង់ដារទី៧:**

មូលដ្ឋានសុខាភិបាលប្រមូលវិភាគនិងប្រើប្រាស់ទិន្នន័យពីការប្រើប្រាស់សេវានិងការថែទាំសេវាប្រកបដោយគុណភាពដោយធ្វើការបែងចែកទិន្នន័យនោះតាមភេទ និងអាយុ ដើម្បីគាំទ្រនូវការធ្វើឱ្យប្រសើរឡើងនូវគុណភាព។ បុគ្គលិកមូលដ្ឋានសុខាភិបាលត្រូវបានគាំទ្រឱ្យចូលរួមបន្តក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាពផងដែរ។

**ស្តង់ដារទី៨:**

យុវវ័យត្រូវបានចូលរួមចំណែកក្នុងការធ្វើផែនការតាមដាននិងវាយតម្លៃនៃសេវាសុខភាពរួមទាំងការធ្វើការសម្រេចចិត្តក្នុងការថែទាំសុខភាពផ្ទាល់ខ្លួនរបស់ពួកគេក៏ដូចជានៅក្នុងទិដ្ឋភាពសមរម្យក្នុងការផ្តល់សេវា។

# ៥. សុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យ ប្រកបដោយមិត្តភាព

## ក. និយមន័យ

- **យុវវ័យ** (young people) គឺជាក្មេងប្រុសក្មេងស្រីឬបុរសស្ត្រីដែលមានអាយុចន្លោះពី១០ទៅ២៤ ឆ្នាំនៅលីវ ឬរៀបការ។
- **សុខភាព** គឺជាស្ថានភាពពេញលេញនូវសុខុមាលភាពរាងកាយផ្លូវចិត្តនិងសង្គម ដោយមិនរាប់បញ្ចូលនូវភាពមានជំងឺ ឬពិការភាពនោះទេ។
- **សេវាសុខភាពយុវវ័យប្រកបដោយមិត្តភាព** មានន័យថាសេវាដែលបានផ្តល់ដោយបុគ្គលិក សុខាភិបាលដែលមានជំនាញនិងសមត្ថភាព ក្នុងគោលបំណងការពារបញ្ហាសុខភាព ធ្វើរោគវិនិច្ឆ័យ និងព្យាបាល។ សេវាទាំងនេះរួមបញ្ចូលទាំងការផ្តល់ព័ត៌មាន ដំបូន្មាននិងការផ្តល់ប្រឹក្សាដោយធានារក្សាការសម្ងាត់យកចិត្តទុកដាក់ដល់យុវវ័យមានសម្ភារ និងឱសថគ្រប់គ្រាន់ មានប្រព័ន្ធបញ្ជូន តម្លៃសេវាសមស្រប មានទីកន្លែង ពេលវេលាដោយឡែកសម្រាប់យុវវ័យនិងមិនរង់ចាំយូរ។

## ខ. សិទ្ធិរបស់យុវវ័យក្នុងការទទួលសេវា

សិទ្ធិសុខភាពបន្តពូជយុវវ័យត្រូវបានបង្កើតឡើងដោយផ្អែកលើសិទ្ធិមនុស្ស និងអនុសញ្ញានៃសិទ្ធិកុមារដើម្បីទទួលបាននូវសុខភាពបន្តពូជដែលមានស្តង់ដារខ្ពស់។ គោលនយោបាយរបស់ក្រសួងសុខាភិបាលស្តីពីការពន្យារកំណើតបានអះអាងយ៉ាងមុតមាំថា "មនុស្សគ្រប់រូបមានសិទ្ធិទទួលបាននូវសុខភាពបន្តពូជដែលមានគុណភាព"។

យុវវ័យគ្រប់រូបមានសិទ្ធិដូចខាងក្រោម៖

១. សិទ្ធិទទួលព័ត៌មានពីការអប់រំសុខភាពបន្តពូជ សុខភាពផ្លូវភេទនិងការពន្យល់រាល់ដំណើរការនៃការផ្តល់សេវា

២. សិទ្ធិទទួលបាននូវសេវាសុខភាពបន្តពូជសុខភាពផ្លូវភេទដែលមានគុណភាព សុវត្ថិភាព និងមានការយកចិត្តទុកដាក់ពីអ្នកផ្តល់សេវាដែលមានជំនាញត្រឹមត្រូវនិងទទួលបានការផ្តល់សេវាបន្ត

៣. សិទ្ធិទទួលបានការថែទាំដោយស្មើភាព និងគ្មានការរើសអើង

៤. សិទ្ធិមានកន្លែងទទួលសេវាស្ងាត់កំបាំង និងរាល់ព័ត៌មានត្រូវបានរក្សាជាការសម្ងាត់

៥. សិទ្ធិក្នុងការសម្រេចចិត្តដោយសេរីក្នុងការជ្រើសរើសសេវាសុខភាពបន្តពូជនៅគ្រប់កន្លែង
៦. សិទ្ធិបញ្ចេញយោបល់ពីការយល់ឃើញអំពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ
៧. សិទ្ធិទទួលបានសមធម៌យេនឌ័រនិងមានការចូលរួមគាំទ្រពីដៃគូ។

## គ. តួនាទីនិងភារកិច្ចរបស់អ្នកផ្តល់សេវាសុខភាព

សេវាសុខាភិបាលដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយជំងឺ ដែលអាចបង្ការបានក្នុងចំណោមយុវវ័យទាក់ទងទៅនឹងសុខភាពផ្លូវភេទអាហាររូបត្ថម្ភ ការប្រើប្រាស់គ្រឿងញៀន សុខភាពផ្លូវចិត្ត និងកត្តាប្រឈមដទៃទៀតដែរ។ អ្នកផ្តល់សេវាសុខភាពតម្រូវឱ្យមានជំនាញ និងចំណេះដឹងគ្រប់គ្រាន់ដើម្បីផ្តល់សេវាប្រកបដោយប្រសិទ្ធភាពនិងត្រូវមានជំនាញទំនាក់ទំនង និងផ្តល់ការពិគ្រោះពិភាក្សា។ អ្នកផ្តល់សេវាមានតួនាទីដ៏សំខាន់ក្នុងការរួមចំណែកជួយឱ្យយុវវ័យមានសុខភាពល្អដោយៈ

### ➢ កំណត់បញ្ហា

- ស្វែងយល់ពីគោលបំណងនិងតម្រូវការរបស់យុវវ័យ
- ស្វែងយល់ពីបញ្ហាដែលយុវវ័យកំពុងប្រឈម
- ធ្វើរោគវិនិច្ឆ័យជំងឺ ទៅតាមកម្រិតមូលដ្ឋានសុខាភិបាល

### ➢ ផ្តល់ព័ត៌មាន និងជំរើសដល់យុវវ័យ

- ផ្តល់ចំណេះដឹងដល់យុវវ័យអំពីកាយវិភាគ និងសរីរៈវិទ្យាប្រព័ន្ធបន្តពូជ ការផ្លាស់ប្តូរនៅពេលពេញវ័យនិងមូលហេតុដែលនាំឱ្យមានផ្ទៃពោះ
- ផ្តល់ព័ត៌មានពីគ្រោះថ្នាក់ដែលអាចកើតមានចំពោះម្តាយនិងកូនពេលមានផ្ទៃពោះនៅវ័យក្មេង ទោះបីជាការមានផ្ទៃពោះដែលគេចង់បាននិងមានផែនការក៏ដោយ
- ផ្តល់សេវាដល់យុវវ័យដែលប្រឈមមុខខ្ពស់ដោយគ្មានការមាក់ងាយរើសអើងឬវិនិច្ឆ័យ
- ផ្តល់ព័ត៌មានជាក់លាក់ស្តីពីការឆ្លងនិងការរីករាលដាលនៃជំងឺកាមរោគ/អេដស៍ជាពិសេសយុវវ័យដែលប្រឈមមុខខ្ពស់
- អ្នកផ្តល់សេវាត្រូវផ្តល់ព័ត៌មានអំពីបញ្ហាសុខភាព បញ្ហាសង្គម និងបញ្ហាសេដ្ឋកិច្ចគ្រួសារដើម្បីចៀសវាងការមានផ្ទៃពោះនៅវ័យក្មេងរបស់ក្រុមយុវវ័យ
- ពិគ្រោះពិភាក្សានិងផ្តល់ព័ត៌មានពីសេវាដែលមានដល់យុវវ័យរួមមាន ការពន្យារកំណើត ពិនិត្យនិងព្យាបាលជំងឺឆ្លងតាមផ្លូវបន្តពូជ ការថែទាំពេលមានផ្ទៃពោះពេលសម្រាលនិងក្រោយសម្រាល ការរំលូតកូនប្រកបដោយសុវត្ថិភាព អាហា រូបត្ថម្ភ គ្រឿងញៀន យេនឌ័រ អំពើហិង្សា សុខភាពផ្លូវចិត្ត ការរំលោភផ្លូវភេទ។ល។

- ជួយផ្តល់ព័ត៌មានអំពីសេវាសុខភាពយុវវ័យដែលមាននៅមូលដ្ឋានសុខាភិបាលដល់ក្រុមយុវវ័យនិងសហគមន៍ ដើម្បីស្វែងរកការគាំទ្រនិងទទួលស្គាល់នូវតម្លៃនៃការផ្តល់សេវាសុខភាព ពីឪពុកម្តាយ អាណាព្យាបាល អាជ្ញាធរ សហគមន៍និងអង្គការដៃគូដើម្បីអនុញ្ញាតឱ្យកូន និងយុវវ័យផ្សេងទៀតក្នុងសហគមន៍បានមកទទួលនិងប្រើប្រាស់សេវាទាំងនោះ។
- ផ្តល់ឱកាសដល់យុវវ័យក្នុងការទទួលបាននូវមធ្យោបាយពន្យារកំណើតប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាពនិងងាយរកបាន។
- លើកទឹកចិត្តដល់យុវវ័យក្នុងការពន្យារទំនាក់ទំនងផ្លូវភេទរហូតដល់ពួកគេអាចទទួលខុសត្រូវចំពោះទំនាក់ទំនងផ្លូវភេទដោយសុវត្ថិភាពបាន។

## ➤ ជួយយុវវ័យក្នុងការសម្រេចចិត្តនិងផ្តល់សេវា

- ជួយគាំទ្រ និងលើកទឹកចិត្តយុវវ័យដើម្បីឱ្យពួកគេធ្វើការសម្រេចចិត្តជ្រើសរើសយក សេវាដែលសមស្រប រួមភេទប្រកបដោយសុវត្ថិភាពពន្យារពេលមានកូននៅវ័យក្មេង
- ផ្តល់សេវាដែលសមស្របសម្រាប់យុវវ័យប្រកបដោយគុណភាព។

## ➤ កិច្ចសហប្រតិបត្តិការតាមរយៈ

- បញ្ជូនយុវវ័យទៅទទួលសេវានៅមូលដ្ឋានសុខាភិបាលផ្សេងទៀតនិងសហការជាមួយអាជ្ញាធរដែនដីដើម្បីបញ្ជូនទៅសេវាសង្គមផ្សេងៗទៀតនៅពេលដែលចាំបាច់។
- សហការជាមួយសហគមន៍ដើម្បីបង្កើនការយកចិត្តទុកដាក់លើសុខភាពរបស់យុវវ័យ
- សហការជាមួយនាយកសាលា គ្រូបង្រៀនដើម្បីស្វែងយល់ពីតម្រូវការរបស់យុវវ័យ និងសារៈសំខាន់នៃការធ្វើការរួមគ្នាដើម្បីបំពេញតម្រូវការរបស់យុវវ័យនិងផ្តោតទៅលើការអប់រំពីសុខភាពផ្លូវភេទគ្រប់ជ្រុងជ្រោយដើម្បីបង្ការការមានផ្ទៃពោះនិងការឆ្លងជំងឺកាមរោគ/អេដស៍។

## ឃ. សេវាសុខភាពដែលយុវវ័យត្រូវទទួលបាន

- អនាម័យនិងថែទាំសុខភាពបឋម
- ពិគ្រោះពិភាក្សាមុនពេលរៀបអាពាហ៍ពិពាហ៍និងការរួមភេទប្រកបដោយសុវត្ថិភាព
- ពន្យារកំណើត (រួមទាំងស្រោមអនាម័យ) និងការពារកំណើតបន្ទាន់
- ពិគ្រោះពិភាក្សាអំពីមេរោគអេដស៍
  (បញ្ជូនសម្រាប់ការធ្វើតេស្តឈាមនិងថែទាំ) និង ពិនិត្យព្យាបាលជំងឺកាមរោគ
- ការថែទាំពេលមានផ្ទៃពោះពេលសម្រាលនិងក្រោយសម្រាល
  (រួមមានតេស្តពិនិត្យរកមើលការមានផ្ទៃពោះ)

- ពិគ្រោះពិភាក្សាយេនឌ័រ, ក្រោយរងនូវអំពើហិង្សាផ្លូវភេទនិងការរំលោភបំពាន (បញ្ជូនទៅរកសេវាដែលពាក់ព័ន្ធ)
- ពិគ្រោះពិភាក្សាមុននិងក្រោយពេលរំលូតកូននិងពន្យារកំណើតបន្ទាប់ពីរំលូតកូន (រួមជាមួយការបញ្ជូនសម្រាប់ការគ្រប់គ្រងនូវផលវិបាកប្រសិនបើចាំបាច់)
- ពិគ្រោះពិភាក្សាអំពីអាហារូបត្ថម្ភ និងព្យាបាលភាពស្លេកស្លាំង
- ពិគ្រោះពិភាក្សាអំពីបញ្ហាគ្រឿងញៀននិងសុរា
- ពិគ្រោះពិភាក្សាពីការការពារជំងឺមហារីកមាត់ស្បូនចំពោះស្ត្រីវ័យក្មេង (អាយុពី ៩-១៣ឆ្នាំ)
- ពិគ្រោះពិភាក្សាពីជំងឺមហារីកដោះ
- ពិគ្រោះពិភាក្សាសេវាសុខភាពផ្លូវចិត្ត។

## ៦. គុណភាពសេវាសុខភាពយុវវ័យប្រកបដោយមិត្តភាព

ក្រសួងសុខាភិបាលបានយកចិត្តទុកដាក់ក្នុងការផ្តល់សេវាសុខភាពដែលមានគុណភាពដោយផ្អែកលើវិសាលភាពទាំង៥ខាងក្រោម៖

| |
|---|
| **១. សមភាពក្នុងការទទួលបានសេវា (Equitable):** យុវវ័យទាំងអស់អាចទទួលបាននូវសេវាសុខភាពដោយស្មើភាពគ្នា។ |
| **លក្ខណៈទូទៅ** |
| » គោលនយោបាយ និងទម្រង់ការនានា មិនបានរិតបន្តឹងដល់ការផ្តល់សេវាសុខភាព |
| » អ្នកផ្តល់សេវាសុខភាព បុគ្គលិកជំនួយការផ្តល់សេវាថែទាំព្យាបាលដល់យុវវ័យប្រកបដោយការយកចិត្តទុកដាក់ និងការគោរពស្មើៗគ្នា ហើយមិនគិតអំពីស្ថានភាពអ្វីឡើយ |
| **២. លទ្ធភាពចូលទៅប្រើប្រាស់សេវា (Accessible): យុវវ័យទាំងអស់អាចទទួលបាននូវសេវាសុខភាពទាំងឡាយដែលមានសម្រាប់ពួកគេ** |
| **លក្ខណៈទូទៅ** |
| » គោលនយោបាយ និងទម្រង់ការនានាដែលធានាដល់ការផ្តល់សេវាដែលឥតគិតថ្លៃ ឬក្នុងតម្លៃសមស្រប ទៅដល់យុវវ័យទាំងអស់ |
| » កន្លែងផ្តល់សេវាបើកដំណើរការក្នុងម៉ោងពេលដែលយុវវ័យងាយស្រួលទៅទទួលបានសេវា |
| » យុវវ័យទទួលបានព័ត៌មានគ្រប់គ្រាន់ត្រឹមត្រូវ អំពីសេវាសុខភាពបន្តពូជនានាដែលមាន និងវិធីទទួលសេវាដែលពួកគេត្រូវការ |
| » ប្រជាជនក្នុងសហគមន៍យល់ដឹងអំពីអត្ថប្រយោជន៍ផ្សេងៗដែលយុវវ័យទទួលបានពីការទៅរកសេវាសុខភាព ហើយពួកគេគាំទ្រដល់ការផ្តល់សេវាសុខភាពទាំងនោះទៅដល់យុវវ័យ |
| » សេវាសុខភាព ឱសថសម្ភារដែលពាក់ព័ន្ធនឹងសុខភាពមួយចំនួនត្រូវបានផ្តល់ទៅឱ្យយុវវ័យនៅក្នុងសហគមន៍ តាមរយៈបុគ្គលិកសុខាភិបាលចុះមូលដ្ឋាន អ្នកធ្វើការតាមមូលដ្ឋានក្រុមទ្រទ្រង់សុខភាពភូមិ និងយុវវ័យផ្ទាល់ |
| **៣. សេវាអាចទទួលយកបាន (Acceptable): យុវវ័យទទួលយកសេវាសុខភាពនានាដែលមានសម្រាប់ពួកគេ** |
| **លក្ខណៈទូទៅ** |
| » គោលនយោបាយ និងទម្រង់ការនានាត្រូវធានាដល់ការរក្សាការសម្ងាត់របស់អតិថិជន |
| » កន្លែងផ្តល់សេវាធានានូវភាពជាឯកជនរបស់អតិថិជន |
| » អ្នកផ្តល់សេវាសុខភាពមានការយកចិត្តទុកដាក់ រួសរាយរាក់ទាក់ចំពោះយុវវ័យ និងមិនធ្វើការវិនិច្ឆ័យរិះគន់លើពួកគេ |

| |
|---|
| » ការរង់ចាំទទួលយកការផ្តល់ប្រឹក្សានៅកន្លែងផ្តល់សេវាមានរយៈពេលខ្លីសមល្មម ទោះបីមានការណាត់ជួបជាមុន ឬមិនមានក៏ដោយ ហើយត្រូវបញ្ជូនបន្តភ្លាមៗទៅរកសេវាសុខភាពដែលមាននៅកន្លែងផ្សេងទៀត ក្នុងករណីចាំបាច់ |
| » កន្លែងផ្តល់សេវាមានបរិស្ថានស្អាត និងមានការស្វាគមន៍រួសរាយរាក់ទាក់ |
| » កន្លែងផ្តល់សេវាមានផ្តល់នូវព័ត៌មាន និងការអប់រំសុខភាព តាមរយៈមធ្យោបាយផ្សព្វផ្សាយជាច្រើនប្រភេទ |
| » យុវវ័យចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំ ការវាយតម្លៃ និងការផ្តល់សេវាសុខភាព |
| **៤. ភាពសមស្របនៃសេវា (Appropriate): សេវាសុខភាពត្រឹមត្រូវសមស្រប ត្រូវបានផ្តល់ឱ្យយុវវ័យពេលគឺសេវាដែលពួកគេត្រូវការ** |
| **លក្ខណៈទូទៅ** |
| » កញ្ចប់សេវាថែទាំសុខភាពដែលចាំបាច់ដើម្បីបំពេញនូវតម្រូវការរបស់យុវវ័យត្រូវបានផ្តល់ឱ្យនៅនឹងកន្លែងផ្តល់សេវា ឬតាមរយៈកន្លែងបញ្ជូនបន្តដែលពាក់ព័ន្ធ |
| **៥. ប្រសិទ្ធភាពនៃសេវា (Effective): សេវាសុខភាពដែលយុវវ័យចង់បានត្រូវបានផ្តល់ឱ្យយ៉ាងត្រឹមត្រូវនិងជួយធ្វើឱ្យសុខភាពកាន់តែប្រសើរឡើង** |
| **លក្ខណៈទូទៅ** |
| » អ្នកផ្តល់សេវាសុខភាពចាំបាច់ត្រូវមានសមត្ថភាពគ្រប់គ្រាន់ដើម្បីអាចធ្វើការជាមួយនឹង យុវវ័យ ព្រមទាំងអាចផ្តល់សេវាសុខភាពដែលពួកគេត្រូវការ |
| » អ្នកផ្តល់សេវាសុខភាពត្រូវប្រើប្រាស់ពិធីសារ និងគោលការណ៍ណែនាំ ដើម្បីផ្តល់នូវសេវាសុខភាពនានា |
| » អ្នកផ្តល់សេវាសុខភាពចំណាយពេលវេលាគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាពដើម្បីជួបជាមួយនឹងយុវវ័យ |
| » កន្លែងផ្តល់សេវាសុខភាពមានសម្ភារឧបករណ៍និងសេវាចាំបាច់ផ្សេងៗដើម្បីផ្តល់សេវា សុខភាពទៅតាមតម្រូវការមូលដ្ឋានសុខាភិបាល |

ដើម្បីឆ្លើយតបទៅនឹងវិសាលភាពខាងលើនិងឱ្យមានភាពងាយស្រួលសម្រាប់យុវវ័យក្នុងការទទួលបានសេវាសុខភាពដែលពួកគេត្រូវការនោះ ការអនុវត្តការងារសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យត្រូវធានាថា៖

- អ្នកផ្តល់សេវាសុខភាព ត្រូវផ្តល់សេវាដល់យុវវ័យឱ្យបានត្រឹមត្រូវ។
- មូលដ្ឋានសុខាភិបាលត្រូវផ្តល់សេវាដែលយុវវ័យត្រូវការ និងជាលក្ខណៈមិត្តភាព។
- យុវវ័យត្រូវដឹងអំពីកន្លែងដែលពួកគេ អាចទទួលបាននិងអាចប្រើប្រាស់បានសេវាសុខភាពតាមតម្រូវការ។

# ៧. លក្ខខណ្ឌក្នុងការបង្កើតឱ្យមានសេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទសម្រាប់យុវវ័យ

## ១. អ្នកផ្តល់សេវា៖

- បានទទួលការបណ្តុះបណ្តាលស្តីពីការផ្តល់សេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យ
- ទទួលបានការគាំទ្រនិងអភិបាលជាទៀងទាត់
- មិនរើសអើងនិងមិនវិនិច្ឆ័យយុវវ័យតាមរយៈការពង្រឹងជំនាញពិគ្រោះពិភាក្សាទំនាក់ទំនងនិងអាកប្បកិរិយា
- រក្សាការសម្ងាត់ ផ្តល់ទំនុកចិត្តនិងគោរពសិទ្ធិអតិថិជនក្នុងការមកទទួលសេវា
- មានពេលវេលាគ្រប់គ្រាន់សម្រាប់ផ្តល់សេវាដល់យុវវ័យ
- ផ្តល់ការពិគ្រោះពិភាក្សាពីសេវាសុខភាពដល់យុវវ័យ
- ផ្តល់ព័ត៌មានអំពីសារសំខាន់នៃការផ្តល់សេវាសុខភាពយុវវ័យដល់ឪពុកម្តាយ/អាណាព្យាបាល និងគ្រូបង្រៀន ក្នុងពេលមានកិច្ចប្រជុំរបស់សាលា
- ផ្តល់ព័ត៌មានអំពីសារសំខាន់នៃការផ្តល់សេវាសុខភាពយុវវ័យដល់ក្រុមយុវវ័យ ស្ថាប័នពាក់ព័ន្ធ និងអង្គការដែលមាននៅក្នុងសហគមន៍
- អនុវត្តតាមគោលការណ៍ណែនាំនិងពិធីសារក្នុងការផ្តល់សេវាដល់យុវវ័យ
- បញ្ជូនយុវវ័យទៅរកសេវាដែលសមស្របនិងទៅតាមកម្រិតនៃការថែទាំដោយផ្អែកទៅលើគោលការណ៍ណែនាំនិងទម្រង់ការ
- ប្រសិនបើអាច គួរស្វែងរកមិត្តអប់រំមិត្តដើម្បីបង្កើនភាពស្និទស្នាលជាមួយយុវវ័យ
- ពិនិត្យតាមដាន ធ្វើរបាយការណ៍ និងប្រើប្រាស់ទិន្នន័យដោយប្រើបញ្ជីផ្ទៀងផ្ទាត់ក្នុងការតាមដានទម្រង់របាយការណ៍ដោយធ្វើការបែងចែកទិន្នន័យនោះតាមភេទនិងអាយុសម្រាប់បញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល

## ២. មូលដ្ឋានសុខាភិបាល៖

- រៀបចំទីកន្លែងដាច់ដោយឡែកឬសមរម្យ (រៀបចំបញ្ចូលជាមួយសេវាសុខភាពបន្តពូជ) ប្រកបដោយបរិយាកាសសមស្របសម្រាប់យុវវ័យ
- សិទ្ធិទទួលសេវារបស់យុវវ័យនិងសេវាសម្រាប់យុវវ័យត្រូវបានដាក់បង្ហាញនៅក្នុងមូលដ្ឋានសុខាភិបាល
- មានបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាលសម្រាប់ធ្វើការអប់រំនៅកន្លែងដែលមានយុវវ័យប្រមូលផ្តុំ (សាលារៀន រោងចក្រ ...)

- មានតារាងពេលវេលាផ្តល់សេវាដល់យុវវ័យហើយពេលវេលានោះមានភាពងាយស្រួលសម្រាប់យុវវ័យក្នុងការមកទទួលសេវា
- ធានាថាមានឱសថ សម្ភារ និងបរិក្ខារប្រើប្រាស់ទៅតាមតម្រូវការនៃកម្រិតមូលដ្ឋានសុខាភិបាល
- មានគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទនៅនឹងកន្លែង
- ត្រូវមានដាក់បង្ហាញនូវព័ត៌មានថ្មីៗដូចជាសម្ភារអប់រំផ្សព្វផ្សាយនិងទំនាក់ទំនង និងសម្ភារជំនួយសម្រាប់ធ្វើការពិគ្រោះពិភាក្សា
- មានបញ្ជីរាយនាមអង្គការដៃគូនិងក្រុមទ្រទ្រង់សុខភាពភូមិដែលគាំទ្រសហគមន៍ដើម្បីបង្កើនការប្រើប្រាស់សេវារបស់យុវវ័យ
- មានផែនការសកម្មភាពនិងបុគ្គលិកសម្រាប់ចុះជួបជាមួយអាជ្ញាធរដើម្បីបង្កើនការគាំទ្រពីពួកគាត់ដល់យុវវ័យក្នុងការមកទទួលសេវា
- មានទម្រង់ការដែលពិព័ណនាពីប្រព័ន្ធបញ្ជូនទៅកាន់សេវាក្នុងនិងក្រៅប្រព័ន្ធសុខាភិបាលរួមមានការផ្តល់សេវាថែទាំនិងព្យាបាលដល់យុវវ័យដែលមានសភាពធ្ងន់ធ្ងរ
- ប្រមូលទិន្នន័យនៃការប្រើប្រាស់សេវាដោយមានការបែងចែកទៅតាមអាយុភេទនិងធ្វើការវាយតម្លៃផ្ទៃក្នុងជាប្រចាំពីគុណភាពនៃការថែទាំ
- មានការបណ្តុះបណ្តាលវិជ្ជាជីវៈបន្តដែលរួមបញ្ចូលការថែទាំសុខភាពយុវវ័យដល់អ្នកផ្តល់សេវា

### ៣. សកម្មភាពក្នុងការរៀបចំសេវា៖

- មានការចូលរួមពីយុវវ័យរួមទាំងយុវវ័យដែលងាយរងគ្រោះក្នុងការរៀបចំបង្កើតឱ្យមាននូវកម្មវិធីយុវវ័យ និងផ្តល់ព័ត៌មានត្រលប់
- ផ្តល់សេវាដល់អតិថិជនតាមលេខរៀងលំដាប់លំដោយ និងពេលវេលារង់ចាំសមស្រប
- តម្លៃសេវាសមស្រប ឬលើកលែងការបង់ថ្លៃ
- ផ្សព្វផ្សាយពីទីតាំងផ្តល់សេវាសុខភាពយុវវ័យនិងសេវាដែលមាន ដោយមានការចូលរួមពីបុគ្គលិកសុខាភិបាលគ្រូបង្រៀន អ្នកស្ម័គ្រចិត្តភូមិ បុគ្គលិកក្រៅរដ្ឋាភិបាល អាជ្ញាធរ ។ល។
- ក្មេងប្រុស និង បុរស ត្រូវបានស្វាគមន៍ក្នុងការមកទទួលសេវា ហើយឱ្យគាត់ជួយណែនាំដៃគូមកទទួលសេវា
- មានផ្តល់សេវាសមស្របដល់យុវវ័យនិងបញ្ជូនក្នុងករណីចាំបាច់។

### ប្រសិនបើអាច៖

- មានក្រុមពិភាក្សាសម្រាប់យុវវ័យ
- មានប្រាក់លើកទឹកចិត្តសម្រាប់អ្នកផ្តល់សេវាផ្អែកលើការអនុវត្តន៍ជាក់ស្តែង។

| កញ្ចប់សេវាសុខភាពយុវវ័យ | ថ្នាក់សហគមន៍ | ថ្នាក់មណ្ឌលសុខភាព | ថ្នាក់មន្ទីរពេទ្យ |
|---|---|---|---|
| ពិគ្រោះពិភាក្សាមុនពេលរៀបអាពាហ៍ពិពាហ៍ | | ✓ | ✓ |
| ការពន្យារកំណើតរួមទាំងស្រោមអនាម័យ | ✓ | ✓ | ✓ |
| ការពិគ្រោះពិភាក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ | | ✓ | ✓ |
| ការបង្ការ ធ្វើរោគវិនិច្ឆ័យ និងគ្រប់គ្រងជំងឺកាមរោគ | | ✓ | ✓ |
| ការថែទាំពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយពេលសម្រាល | | ✓ | ✓ |
| ការបង្ការការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន | | ✓ | ✓ |
| ការព្យាបាលបឋមក្រោយការរំលោភបំពានផ្លូវភេទ | | ✓ | ✓ |
| រំលូតកូនដោយសុវត្ថិភាពនិងការថែទាំក្រោយរំលូត | | ✓ | ✓ |
| ឱសថប្រឆាំងមេរោគអេដស៍ | | | ✓ |
| សុខភាពផ្លូវចិត្ត | | | ✓ |
| មហារីកមាត់ស្បូន (វ៉ាក់សាំងបង្ការ និងការស្រាវជ្រាវរក កោសិកាត្រៀមមហារីកមាត់ស្បូន) | | ✓ | ✓ |
| អាហារូបត្ថម្ភ និងព្យាបាលភាពស្លេកស្លាំង | | ✓ | ✓ |
| គ្រឿងញៀន | | | ✓ |
| បញ្ជូនទៅមូលដ្ឋានសុខាភិបាលឬកន្លែងផ្តល់សេវាសមស្របដទៃទៀត | ✓ | ✓ | ✓ |

# ៨. ការគាំទ្រនៅមូលដ្ឋាន

## ការផ្តល់សេវាសម្រាប់យុវវ័យអាចធ្វើឡើងតាមគំរូច្រើនបែបដូចខាងក្រោម៖

### សេវាសុខភាពចល័ត

សេវាសុខភាពចល័តជាសេវាដែលបានផ្តល់ឱ្យយុវវ័យ ទៅដល់តំបន់ដែលពួកគេត្រូវការហើយអាចជាសេវាដែលមានប្រសិទ្ធភាព ក្នុងការផ្តល់សេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ យុវវ័យ។ យន្តការនៃការផ្តល់សេវាសុខភាពចល័តមានច្រើនបែបដូចជាគ្លីនិកចល័តការចុះផ្តល់សេវានៅមូលដ្ឋាន និងតាមរយៈសកម្មភាពទិវាសុខភាពនានា។ ការផ្តល់សេវាតាមរយៈយន្តការទាំងនេះត្រូវមានលក្ខណៈមិត្តភាពនិងមានគុណភាពហើយប្រាកដថាបុគ្គលិកដែលផ្តល់សេវា ត្រូវបានទទួលការបណ្តុះបណ្តាលអំពីការផ្តល់សេវាសុខភាពបន្តពូជយុវវ័យ មិនវិនិច្ឆ័យធានានូវភាពជាឯកជននិងរក្សាការសម្ងាត់។ ការ ផ្តល់សេវាសុខភាពចល័តអាចធ្វើនៅទីកន្លែងផ្សេងៗដូចជានៅភូមិ សាលារៀនកន្លែងធ្វើការ (ឧ. រោងចក្រ) ពន្ធនាគារ មូលដ្ឋានកងទ័ព ក្លិបកីឡា មណ្ឌលកុមារកំព្រា។ល។

### សេវាសុខភាពនៅសហគមន៍

សេវាសុខភាពនៅសហគមន៍ជាសេវាដែលបានផ្តល់ដោយភ្នាក់ងារដែលមិនមែនជាបុគ្គលិកសុខាភិបាលប៉ុន្តែបានទទួលការបណ្តុះបណ្តាលអំពីការអប់រំសុខភាព ដូចជាការពិគ្រោះពិភាក្សាអំពីមធ្យោបាយពន្យារកំណើតការធ្វើតេស្តឈាមរកមេរោគអេដស៍ ការត្រៀមជុំវិញកំណើតអនាម័យ ការថែទាំសុខភាពបឋម អាហារូបត្ថម្ភ ព័ត៌មានស្តីការផ្តល់ថ្នាំបង្ការ ការបង្ការការឆ្លងជំងឺកាមរោគ/អេដស៍ គ្រឿងញៀន យេនឌ័រការ រំលោភបំពានផ្លូវភេទនិងអំពើហិង្សាក្នុងគ្រួសារ និងការផ្តល់សេវាដល់យុវវ័យ ដូចជាស្រោមអនាម័យ ថ្នាំគ្រាប់ពន្យារកំណើត ថ្នាំជាតិដែក និងថ្នាំទម្លាក់ព្រូន។

ការផ្តល់សេវាសុខភាពនៅសហគមន៍អាចធ្វើនៅទីកន្លែងផ្សេងៗនៅភូមិ។

### ឱសថស្ថាន

ឱសថស្ថានជាកន្លែងផ្តល់សេវាមានភាពងាយស្រួល រហ័សនិងអនាមិកដល់យុវវ័យក្នុងការទៅទទួលយកសេវា។ ដោយមូលហេតុនេះយុវវ័យភាគច្រើនចូលចិត្តទៅស្វែងរកសេវាសុខភាពផ្លូវ ភេទ សុខភាពបន្តពូជរួមមានស្រោមអនាម័យ ថ្នាំគ្រាប់ពន្យារកំណើត ថ្នាំគ្រាប់ការពារកំណើតបន្ទាន់ ។ល។ ឱសថស្ថានអាចចាត់ទុកជាយន្តការមួយក្នុងការផ្តល់សេវាសុខភាពយុវវ័យ ប្រសិនបើឱសថការីនិងបុគ្គលិកឱសថស្ថានបានទទួលការបណ្តុះបណ្តាល និងផ្តល់នូវការពិគ្រោះពិភាក្សាត្រឹមត្រូវ ពេញលេញ មិនធ្វើការវិនិច្ឆ័យដល់យុវវ័យប្រកបដោយភាពឯកជន និងរក្សាការសម្ងាត់ផ្តល់សម្ភារអប់រំស្តីពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ និងធ្វើការបញ្ជូនទៅមូលដ្ឋានសុខាភិបាលតាមតម្រូវការបន្ថែម។

## សេវាសុខភាពនៅសាលារៀន

យោងតាមច្បាប់អប់រំមាត្រាទី៤១ (ឆ្នាំ២០០៧)សេវាសុខភាព ត្រូវធ្វើឡើងដោយសហការជាមួយក្រសួងសុខាភិបាលនិងក្រសួងអប់រំយុវជននិងកីឡា។ ដើម្បីស្របជាមួយនឹងកម្មវិធីអប់រំសុខភាពផ្លូវភេទគ្រប់ជ្រុងជ្រោយរបស់ក្រសួងអប់រំយុវជននិងកីឡា សម្រាប់សិស្សថ្នាក់ទី៥ដល់ទី៨និងថ្នាក់ទី១០ដល់ទី១១ដើម្បីផ្តល់នូវចំណេះដឹងបំណិនជីវិតដល់សិស្សានុសិស្ស អំពីសុខភាពបន្តពូជសុខភាពផ្លូវភេទរួមមានៈភេទ យេនឌ័រ អំពើហឹង្សា និងគ្រឿងញៀន ការយល់ដឹងអំពីសិទ្ធិមនុស្ស ការពន្យារកំណើត ។ល។

## តួនាទីរបស់គ្រូបង្រៀន :

ផ្តល់ព័ត៌មានដល់សិស្សានុសិស្សពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ សេវាដែលអាចទទួលយកបាននៅមណ្ឌលសុខភាពនិងជួយធ្វើការបញ្ជូន។ អ្នកផ្តល់សេវាគឺជាបណ្តាញទំនាក់ទំនងមួយដ៏ល្អបំផុតដើម្បីបង្កើតនូវទំនុកចិត្តនិងភាពជឿជាក់ដល់សិស្សានុសិស្សនិងបញ្ជូនពួកគេឱ្យទៅទទួលសេវានៅមូលដ្ឋានសុខាភិបាល។ ក្រសួងអប់រំនិងក្រសួងសុខាភិបាលត្រូវធ្វើការសហការយ៉ាងជិតស្និទ្ធដើម្បីឱ្យការ ផ្តល់ព័ត៌មានពីការទទួលសេវាសុខភាពអាចប្រព្រឹត្តទៅបាននៅសាលារៀន។

គំនូសបំព្រួញខាងក្រោម រៀបរាប់ពីកិច្ចសហការ រវាងមូលដ្ឋានសុខាភិបាល សាលារៀន និងសហគមន៍ដើម្បីលើកកម្ពស់សុខភាពយុវវ័យ។



បន្ថែមពីលើសកម្មភាពដែលវិស័យសុខាភិបាលទទួលខុសត្រូវជាចំបង ក្នុងការផ្តល់សេវា សុខភាពជាការចាំបាច់ណាស់ដែលវិស័យសុខាភិបាលត្រូវមានទំនាក់ទំនងជាមួយវិស័យអប់រំ លើផ្នែក សំខាន់ៗជាច្រើនដូចជា៖

## កិច្ចសហការរវាងវិស័យសុខាភិបាលនិងវិស័យអប់រំ៖

- វិស័យសុខាភិបាលនិងវិស័យអប់រំត្រូវសហការណ៍ជួយគាំទ្រដើម្បីពង្រឹងនិងសម្របសម្រួលដល់ការធ្វើអន្តរាគមន៍ពីការផ្តល់សេវាសុខភាពដល់យុវវ័យ។
- វិស័យអប់រំអនុវត្តនូវកម្មវិធីសិក្សានិងផ្តល់ព័ត៌មានស្តីពីការអប់រំសុខភាពផ្លូវភេទ និងសេវាសុខភាពយុវវ័យដល់សិស្ស/និស្សិតព្រមទាំងជួយគាំទ្រនូវការប្រើប្រាស់សេវាទាំងនោះ។
- វិស័យសុខាភិបាលត្រូវដើរតួយ៉ាងសំខាន់ក្នុងការគាំទ្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសុខភាពបន្តពូជនិងសុខភាពផ្លូវភេទដែលបានផ្តួចផ្តើមដោយសាលាក្នុងការផ្តល់ព័ត៌មានអប់រំនិងជួយបង្កើនជំនាញពិគ្រោះពិភាក្សាដល់គ្រូបង្រៀនដើម្បីធានាថា ព័ត៌មានដែលបានផ្តល់តាមរយៈសាលាគឺត្រឹមត្រូវទៅតាមបច្ចេកទេសនិងត្រូវនឹងសារអប់រំដទៃទៀតដែលយុវវ័យត្រូវទទួលបាន
- បុគ្គលិកសុខាភិបាលមានតួនាទីចុះធ្វើការអប់រំ ផ្តល់ព័ត៌មាន ពិគ្រោះពិភាក្សាដល់យុវវ័យដែលជាសិស្ស និស្សិត នៅតាមសាលា ក៏ដូចជាផ្តល់ព័ត៌មានស្តីពីសារសំខាន់នៃសុខភាព យុវវ័យដល់ឪពុកម្តាយ/អាណាព្យាបាល និងគ្រូបង្រៀន នៅអំឡុងពេលមានកិច្ចប្រជុំរបស់សាលា។

## កិច្ចសហការរវាងវិស័យសុខាភិបាលនិងសហគមន៍៖

- អ្នកផ្តល់សេវាសុខភាពមានតួនាទីយ៉ាងសំខាន់ ក្នុងការទាក់ទងជាមួយសហគមន៍ដែលមាន យុវវ័យខ្លួនឯងផ្ទាល់ ក្រុមគ្រួសារ ក្រុមទ្រទ្រង់សុខភាពភូមិ អ្នកអប់រំនៅមូលដ្ឋានគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព បណ្តាញយុវវ័យគណៈកម្មការទទួលបន្ទុកកិច្ចការនារីនិងកុមារដើម្បីបង្កើនចំណេះដឹងនិងជំនាញក្នុងការផ្តល់ព័ត៌មានស្តីពីសុខភាពយុវវ័យសេវាដែលមាននៅមូលដ្ឋានសុខាភិបាលបញ្ជូននិងគាំទ្រយុវវ័យទៅទទួលសេវា។ អ្នកផ្តល់សេវាក៏មានតួនាទីសំខាន់ផងដែរក្នុងការចុះផ្ទាល់តាមមូលដ្ឋានដើម្បីផ្តល់ការអប់រំពិគ្រោះពិភាក្សាពាក់ព័ន្ធនឹងសុខភាពយុវវ័យ ផ្តល់សេវាបញ្ជូននិងតាមដាន។
- សហគមន៍ជួយគាំទ្រដល់វិស័យសុខាភិបាលក្នុងការសម្របសម្រួលផ្តល់ព័ត៌មានអប់រំ បញ្ជូនតាមដាន និងផ្តល់ព័ត៌មានត្រឡប់។

### កិច្ចសហការរវាងសហគមន៍ និងវិស័យអប់រំ

- ឪពុកម្តាយអាណាព្យាបាលមួយចំនួនអាចនឹងមានទស្សនៈ និងការបារម្ភពីឥទ្ធិពលនៃការអប់រំទាក់ទងនឹងសុខភាពផ្លូវភេទ។ ពេលខ្លះការបារម្ភទាំងនេះដោយសារកង្វះព័ត៌មានឬមិនទាន់យល់ច្បាស់អំពីគោលបំណងនិងផលប្រយោជន៍នៃការអប់រំសុខភាពផ្លូវភេទ ឬការយល់ឃើញនៃផ្នត់គំនិតសង្គម។ ការគាំទ្រពីមជ្ឈដ្ឋានខាងក្រៅគួរត្រូវបានផ្តល់ឱ្យដល់ឪពុកម្តាយអាណាព្យាបាល និងសមាជិកសំខាន់ៗរបស់សហគមន៍ដើម្បីធ្វើការផ្លាស់ប្តូរផ្នត់គំនិតសង្គមនិងការបារម្ភរបស់ពួកគាត់ ព្រោះពួកគាត់ជាមនុស្សមានឥទ្ធិពលទៅលើយុវវ័យ។
- វាមានសារសំខាន់ណាស់ដែលត្រូវធ្វើការចែករំលែកនូវការបារម្ភរបស់សាលា និងឪពុកម្តាយអាណាព្យាបាល ក្នុងការលើកកម្ពស់សុវត្ថិភាព និងសុខភាពល្អរបស់យុវវ័យ។ ការបារម្ភរបស់ឪពុកម្តាយ ឬអាណាព្យាបាលអាចត្រូវបានដោះស្រាយ តាមរយៈការតម្រង់ទិសពីប្រធានបទដែលត្រូវអប់រំទៅកូន និងបង្កើនជំនាញទំនាក់ទំនងរបស់ពួកគាត់ឱ្យកាន់តែបើកចំហនិងនិយាយការពិតអំពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ជាមួយនឹងកូន លុបបំបាត់ការភ័យខ្លាច និងគាំទ្រកិច្ចប្រឹងប្រែងរបស់សាលារៀន ដើម្បីឱ្យផ្តល់ការអប់រំសុខភាពបន្តពូជនិងសុខភាពផ្លូវភេទប្រកបដោយគុណភាព។

| |
|---|
| វិស័យសុខាភិបាល វិស័យអប់រំនិងសហគមន៍ចាំបាច់ត្រូវមានកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធក្នុងការកៀរគរនិងលើកទឹកចិត្តយុវវ័យឱ្យចូលរួមក្នុងការបង្កើត និងរៀបចំផែនការអនុវត្តសកម្មភាព តាមដាន វាយតម្លៃនិងផ្តល់ព័ត៌មានត្រឡប់។ |

# ៩ អភិបាលគាំទ្រ ការពិនិត្យតាមដាន និង វាយតម្លៃ

## ១. និយមន័យ

### ការអភិបាលគាំទ្រ

គឺជាសកម្មភាពនិងទម្រង់ការងារមួយដែលអ្នកអភិបាលបានចុះពិនិត្យមើល និងតម្រង់ទិសនូវអ្វីដែលអ្នកផ្តល់សេវាបានធ្វើរួមមាន ពិនិត្យលើជំនាញ ការរៀបចំសេវា ការគ្រប់គ្រងសេវា និងកំណត់ត្រា។ល។ ការអភិបាលគាំទ្រធ្វើឡើងជាប្រព័ន្ធដែលអ្នកអភិបាលត្រូវជួយគាំទ្រដល់អ្នកផ្តល់សេវា និងពិភាក្សាលើការផ្តល់សេវារបស់ពួកគេឱ្យបានកាន់តែប្រសើរឡើង។

### ការពិនិត្យតាមដាន

គឺជាការតាមដានសកម្មភាពការងារដើម្បីកំណត់ពីចំណុចខ្លាំង និងចំណុចខ្សោយនៃសេវានៅក្នុងដំណើរការបន្ត។ ការពិនិត្យតាមដានធ្វើឡើងតាមរយៈការអភិបាល ការបង្វឹកបង្ហាត់ ការចុះជួយគាំទ្រលើកទឹកចិត្ត ការវាយតម្លៃខ្លួនឯង(ផ្ទៃក្នុង) និងការវាយតម្លៃពីគុណភាពនៃការផ្តល់ការថែទាំដោយប្រើបញ្ជីផ្ទៀងផ្ទាត់ជាលក្ខណៈស្តង់ដារ។

### ការវាយតម្លៃ

គឺជាការវាស់វែងពីប្រសិទ្ធភាពនិងគុណភាពនៃសេវាដែលធ្វើឡើង ក្នុងពេលចាប់ផ្តើមកំពុងដំណើរការនិងចុងបញ្ចប់គម្រោងក្នុងគោលបំណងជួយដល់អ្នកផ្តល់សេវាសុខភាព និងអ្នកគ្រប់គ្រងក្នុងការលើកកម្ពស់គុណភាពសេវា និងបង្កើនការប្រើប្រាស់សេវាឱ្យបានប្រសើរឡើងក៏ដូចជាទទួលបាននូវការគាំទ្រសម្រាប់ការពង្រីកសេវា និងមាននិរន្តភាព។ ការវាយតម្លៃត្រូវពិនិត្យលើវិសាលភាពទាំង៥ដូចជាសមភាពក្នុងការទទួលបានសេវា លទ្ធភាពចូលទៅប្រើប្រាស់សេវា សេវាអាចទទួលយកបាន ភាពសមស្របនៃសេវា និងប្រសិទ្ធភាពនៃសេវា។

## ២. ដំណើរការនៃការពិនិត្យតាមដាននិងអភិបាលគាំទ្រ

ការពិនិត្យតាមដាន និងអភិបាលគាំទ្រ ដើម្បីជំរុញការផ្តល់សេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាព មានប្រសិទ្ធភាពនិងគុណភាពត្រូវធ្វើឡើងមាន៣លំដាប់ថ្នាក់គឺថ្នាក់ជាតិ ថ្នាក់ខេត្ត/ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាល៖

- ថ្នាក់ជាតិ ធ្វើការពិនិត្យតាមដាន និងអភិបាលគាំទ្រទៅថ្នាក់ខេត្ត/ស្រុកប្រតិបត្តិ មូលដ្ឋានសុខាភិបាល និងសហគមន៍។

- ថ្នាក់ខេត្តធ្វើការពិនិត្យតាមដាន និងអភិបាលគាំទ្រ ទៅថ្នាក់ស្រុកប្រតិបត្តិ មូលដ្ឋានសុខាភិបាល និងសហគមន៍ផ្ទាល់។
- ថ្នាក់មូលដ្ឋានសុខាភិបាលធ្វើការពិនិត្យតាមដាន និងអភិបាលគាំទ្រ នៅនឹងមូលដ្ឋានសុខាភិបាលផ្ទាល់ទៅលើសេវាយុវវ័យ (អ្នកផ្តល់សេវា ទីតាំង សម្ភារ សេវា គុណភាពសេវា...) និងទៅសហគមន៍។

## ភារកិច្ចរបស់ថ្នាក់ជាតិសម្រាប់សេវាសុខភាពបន្តពូជយុវវ័យ

កម្មវិធីជាតិសុខភាពបន្តពូជមានតួនាទីក្នុងការធ្វើឱ្យសេវាសុខភាពបន្តពូជយុវវ័យប្រកបដោយមិត្តភាព គុណភាព ត្រូវមានសកម្មភាព និងមុខងារដូចខាងក្រោម៖

### ក.ជំហាននៃការអនុវត្ត ៖

- ✓ ធ្វើការវិភាគស្ថានភាពសុខភាពយុវវ័យ ឬពិនិត្យនិងជ្រើសរើសសកម្មភាពអាទិភាពដែលឆ្លើយតបទៅនឹងស្ថានភាពសុខភាពយុវវ័យ
- ✓ បង្កើតយុទ្ធសាស្ត្រដើម្បីពង្រឹងសេវាសុខភាព ឆ្លើយតបទៅនឹងសុខភាពយុវវ័យ នៅក្នុងបរិបទឆ្លើយតបជាពហុវិស័យឱ្យបានទូលំទូលាយ
- ✓ បង្កើតស្តង់ដារគុណភាពសេវាថ្នាក់ជាត សម្រាប់ផ្តល់សេវាសុខភាពដល់យុវវ័យ
- ✓ ផ្សព្វផ្សាយការអនុម័តអំពីស្តង់ដារថ្នាក់ជាតិទៅដល់ថ្នាក់ខេត្ត ថ្នាក់ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព
- ✓ បង្កើតឧបករណ៍ សម្ភារ ដើម្បីជំរុញនិងណែនាំពីការអនុវត្ត និងតាមដាននូវសកម្មភាពដែលបានអនុវត្ត និងតាមដានកម្រិតស្តង់ដារគុណភាពសេវា
- ✓ បង្កើតផែនការសម្រាប់ពង្រីកសកម្មភាពសេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ យុវវ័យប្រកបដោយមិត្តភាពដើម្បីអនុវត្តតាមកម្រិតស្តង់ដារគុណភាពសេវាឱ្យបាន ទូទាំងប្រទេស
- ✓ ធ្វើការណែនាំតម្រង់ទិស និងលើកទឹកចិត្តការចូលរួមរបស់ថ្នាក់ខេត្ត ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាល។

### ខ.សកម្មភាពដែលត្រូវអនុវត្ត ៖

- ✓ បង្កើតគោលការណ៍ណែនាំថ្នាក់ជាតិអំពីសេវាសុខភាពបន្តពូជយុវវ័យប្រកបដោយមិត្តភាពនិងទំនាក់ទំនងរវាងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត ហើយត្រូវប្រាកដថា ពួកគេអនុវត្តតាមគោលការណ៍ណែនាំនេះ។
- ✓ ត្រូវប្រាកដថា ថ្នាក់ខេត្ត ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាលមានធនធានគ្រប់គ្រាន់ដើម្បីឱ្យពួកគេអាចផ្តល់សេវាសុខភាពបន្តពូជយុវវ័យប្រកបដោយមិត្តភាពបាន។

- ✓ បង្កើត ឬអនុម័តវិធីសាស្ត្រនិងឧបករណ៍ដែលមានស្រាប់ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើង នូវសមត្ថភាព និងអាកប្បកិរិយារបស់អ្នកផ្តល់សេវា ហើយត្រូវមានសម្ភារអប់រំងាយស្រួលទាក់ទងជាមួយយុវវ័យ។
- ✓ ផ្តល់ឯកសារនិងចែករំលែកបន្តនូវបទពិសោធន៍ដើម្បីពង្រឹងសេវាសុខភាពឱ្យឆ្លើយតបទៅនឹងតម្រូវការសុខភាពរបស់យុវវ័យ។

## ភារកិច្ចរបស់ថ្នាក់ខេត្តនិងស្រុកប្រតិបត្តិសម្រាប់សេវាសុខភាពបន្តពូជយុវវ័យ

ដើម្បីអនុវត្តនូវស្តង់ដារសេវាសុខភាពបន្តពូជយុវវ័យឱ្យកាន់តែប្រសើរឡើង ថ្នាក់ដឹកនាំ សុខាភិបាលខេត្ត ស្រុកប្រតិបត្តិ និង ក្រុមការងារត្រូវអនុវត្តនូវសកម្មភាព និងមុខងារដូចខាងក្រោម៖

### ក.ជំហាននៃការអនុវត្ត ៖

- ✓ ធ្វើការណែនាំតម្រង់ទិស និង លើកទឹកចិត្តដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធនៅខេត្តនិងស្រុកប្រតិបត្តិដើម្បីពង្រឹងសេវាសុខភាពយុវវ័យ
- ✓ ដឹកនាំប្រមូលព័ត៌មានអំពីទីតាំង និងសេវាដែលមានស្រាប់នៅក្នុងខេត្ត និងស្រុកប្រតិបត្តិ
- ✓ បង្កើតផែនការសម្រាប់ពង្រីកការផ្តល់សេវាសុខភាពបន្តពូជយុវវ័យប្រកបដោយមិត្តភាពទូទាំងខេត្ត/ស្រុកប្រតិបត្តិ
- ✓ ណែនាំតម្រង់ទិសដល់អ្នកគ្រប់គ្រងនៅស្រុកប្រតិបត្តិនិងមូលដ្ឋានសុខាភិបាល។

### ខ.សកម្មភាពដែលត្រូវអនុវត្ត ៖

- ✓ ភ្ជាប់ទំនាក់ទំនងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការជួយធ្វើយ៉ាងណាឱ្យ ប្រាកដថានៅមូលដ្ឋានសុខាភិបាល មានធនធានគ្រប់គ្រាន់សម្រាប់ផ្តល់សេវាទៅឱ្យយុវវ័យរួមមាន បុគ្គលិកគ្រប់គ្រាន់ គោលការណ៍ណែនាំសម្រាប់អនុវត្ត សម្ភារអប់រំ ឧបករណ៍ ឱសថនិងការផ្គត់ផ្គង់ផ្សេងៗ។
- ✓ សម្របសម្រួលបង្កើនទំនាក់ទំនងការងារ រវាងប្រធាន បុគ្គលិកសុខាភិបាល និងមន្ត្រីនៅក្នុងវិស័យដទៃទៀតដែលពាក់ព័ន្ធ ឬ អង្គការផ្សេងៗដែលធ្វើការនៅក្នុងមូលដ្ឋាននោះ។
- ✓ គាំទ្រប្រធាន និងបុគ្គលិកសុខាភិបាលក្នុងការអនុវត្តការវាយតម្លៃពីការផ្តល់សេវាសុខភាពដែលមានគុណភាពនិងប្រើប្រាស់ចំណុចខ្វះខាត ជាមូលដ្ឋានដើម្បីដោះស្រាយបញ្ហា
- ✓ គាំទ្រប្រធាន និងបុគ្គលិកសុខាភិបាលក្នុងការអនុវត្តសកម្មភាពសំខាន់ៗនៅមូលដ្ឋានសុខាភិបាលនិងសហគមន៍
- ✓ ថ្នាក់ស្រុកប្រតិបត្តិត្រូវបានធ្វើការពិនិត្យតាមដានជាផ្លូវការពីថ្នាក់ជាតិក្នុងកិច្ចសហការជាមួយនឹងថ្នាក់ខេត្ត

✓ ការតាមដាននេះត្រូវធ្វើការវាយតម្លៃបែបគាំទ្របង្វឹកជាជំហានៗ។

ការអភិបាលការងារសុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យថ្នាក់ខេត្តត្រូវបានធ្វើឡើងដោយមន្ត្រីថ្នាក់ជាតិនិងមានកិច្ចសហប្រតិបត្តិការជាមួយមន្ទីរសុខាភិបាលខេត្ត។ទន្ទឹមនឹងនេះការអភិបាលត្រូវវាយតម្លៃថ្នាក់ដឹកនាំសុខាភិបាលខេត្តពីការចូលរួមរបស់គាត់ក្នុងការអនុវត្តពង្រឹងប្រព័ន្ធសុខាភិបាលដើម្បីឆ្លើយតបទៅនឹងសុខភាពយុវវ័យ។

## ភារកិច្ចរបស់ថ្នាក់មូលដ្ឋានសុខាភិបាលសម្រាប់សេវាសុខភាពបន្តពូជយុវវ័យ

អ្នកគ្រប់គ្រងនៅមូលដ្ឋានសុខាភិបាលត្រូវមានសកម្មភាព និងមុខងារដូចខាងក្រោម ៖

### ក.ជំហាននៃការអនុវត្ត ៖

✓ ធ្វើការណែនាំតម្រង់ទិសដល់បុគ្គលិកមូលដ្ឋានសុខាភិបាល

✓ ធ្វើការវាយតម្លៃគាំទ្រ និងកំណត់អំពីគុណភាពសេវាដែលខ្វះខាត

✓ បង្កើតផែនការកែលំអគុណភាពសេវា

✓ ពិនិត្យមើលឱ្យបានដិតដល់ពីការអនុវត្តផែនការកែលំអគុណភាពសេវា

✓ អនុវត្តការវាយតម្លៃគុណភាពឡើងវិញដើម្បីពិនិត្យតាមដានពីការរីកចំរើន ធៀបទៅនឹងការអនុវត្តពីការផ្តល់សេវាសុខភាពស្តង់ដារដល់យុវវ័យពីមុនមក។

### ខ.សកម្មភាពដែលត្រូវអនុវត្ត ៖

✓ សហការជាមួយស្រុកប្រតិបត្តិដើម្បីប្រាកដថាថ្នាក់មូលដ្ឋានសុខាភិបាលមានធនធានគ្រប់គ្រាន់សម្រាប់ផ្តល់សេវាសុខភាពដល់យុវវ័យ។

✓ ជួយគាំទ្របុគ្គលិកមូលដ្ឋានសុខាភិបាលក្នុងការផ្តល់សេវាឱ្យមានប្រសិទ្ធភាព និងប្រកបដោយមិត្តភាព

✓ បង្កើតនិងថែរក្សាទំនាក់ទំនងសហគមន៍ ក្នុងការជួយគាំទ្រការផ្តល់សេវាសុខភាពបន្តពូជយុវវ័យ

ការអភិបាលថ្នាក់មូលដ្ឋានសុខាភិបាល ត្រូវបានអនុវត្តដោយ មន្ត្រីថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុកប្រតិបត្តិ ដោយមានកិច្ចសហការពីបុគ្គលិកមូលដ្ឋានសុខាភិបាល។ ការអភិបាលនឹងរួមបញ្ចូលនូវការប៉ាន់ប្រមាណនូវជំហាននិងសកម្មភាពដូចបានរៀបរាប់ខាងលើដើម្បីបញ្ជាក់ថាសកម្មភាពទាំងនោះត្រូវបានអនុវត្ត។ បន្ថែមពីលើនេះទៀត ការអភិបាលត្រូវបានវាយតម្លៃពីគុណភាពនៃមូលដ្ឋាន សុខាភិបាលនិងការប្រើប្រាស់សេវារបស់យុវវ័យ។

## ៣. ដំណើរការវាយតម្លៃ

ការវាយតម្លៃដំបូងនិងចុងបញ្ចប់ត្រូវធ្វើឡើង ដោយការចូលរួមពីបុគ្គលិករបស់មូលដ្ឋាន សុខាភិបាលឬ/និងសហគមន៍ដែលនៅក្នុងតំបន់គ្របដណ្តប់។ ការវាយតម្លៃដំបូងត្រូវធ្វើឡើងនៅពេលចាប់ផ្តើមអនុវត្តគម្រោងហើយការវាយតម្លៃចុងបញ្ចប់នឹងត្រូវធ្វើឡើងនៅរយៈពេល៥ឆ្នាំបន្ទាប់ពីចាប់ ផ្

តើមដើម្បីបង្ហាញនូវផលប៉ះពាល់យូរអង្វែង។ ក្រៅពីនេះសិក្ខាសាលាបូកសរុបប្រចាំឆ្នាំត្រូវបានរៀបចំឡើងជាមួយនឹងបុគ្គលិកអនុវត្តផ្ទាល់ដើម្បីបូកសរុបការងារដែលបានអនុវត្តក្នុងឆ្នាំកន្លងមកនិងចែករំលែកបទពិសោធន៍ដែលមានកន្លងមក។

ដំណើរការនៃការវាយតម្លៃត្រូវរួមបញ្ចូលនូវវិធីសាស្រ្តដូចខាងក្រោម៖

- ប្រើប្រាស់វិធីសាស្រ្តវាយតម្លៃតាមបែបចូលរួម
- តម្លាភាពក្នុងអំឡុងដំណើរការទាំងមូល
- ប្រើប្រាស់ភាសាជាលក្ខណយុវវ័យមិត្តភាពនិងមានទំនាក់ទំនងល្អ
- ប្រមូលទិន្នន័យក្នុងសិក្ខាសាលាដែលមានតែយុវវ័យចូលរួម
- មានភាពបត់បែនក្នុងការរៀបចំវាយតម្លៃ
- ពិភាក្សាអំពីចំណុចខ្លាំងនិងចំណុចខ្សោយនៃវិធីសាស្រ្តដែលបានប្រើប្រាស់នៅចុងបញ្ចប់សិក្ខាសាលា
- សិក្ខាសាលាពិគ្រោះយោបល់អំពីការប៉ាន់ប្រមាណលទ្ធផលដំបូងនៃការវិភាគទិន្នន័យ

ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធអភិបាល និងវាយតម្លៃដោយមានការបែងចែកទិន្នន័យទៅតាម អាយុ ភេទ... ក្នុងអំឡុងពេលប្រមូល វិភាគនិងរាយការណ៍។

## សូចនាករដែលបានជ្រើសរើសសម្រាប់សេវាសុខភាពរបស់យុវវ័យ

| ល.រ | សូចនាករ | ប្រភព | ទិន្នន័យដើមគ្រា២០១៤ | ផែនការឆ្នាំ ២០១៨ | ផែនការឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ១ | ភាគរយស្ត្រីវ័យក្មេងមានផ្ទៃពោះ អាយុ១៥-១៩ឆ្នាំ (CDHS) | CDHS | ១២% | ១០.% | ៨% |
| ២ | ភាគរយស្ត្រីវ័យក្មេងមានផ្ទៃពោះ អាយុ < ២០ឆ្នាំ (HIS) | HIS | N/A | | |
| ៣ | ភាគរយស្ត្រីវ័យក្មេងអាយុ១៥-១៩ឆ្នាំដែលកំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើត | CDHS | ៣.២% | ៣.៥% | ៤% CDHS |
| ៤ | ភាគរយស្ត្រីវ័យក្មេងអាយុ < ២០ឆ្នាំដែលកំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើត | HIS | N/A | | |
| ៥ | ភាគរយស្ត្រីវ័យក្មេងអាយុ១៥-១៩ឆ្នាំដែលមិនអាចទទួលបានមធ្យោបាយពន្យារកំណើតតាមតម្រូវការ | CDHS | ១២.៦% | | ១២% CDHS |
| ៦ | ភាគរយស្ត្រីវ័យក្មេងអាយុ២០-២៤ឆ្នាំដែលមិនអាចទទួលបានមធ្យោបាយពន្យារកំណើតតាមតម្រូវការ | CDHS | ១១.៦% | | ១១% CDHS |
| ៧ | ភាគរយនៃយុវវ័យដែលជាក្មេងស្រីអាយុ១៥-១៩ឆ្នាំ មានចំណេះដឹងគ្រប់ជ្រុងជ្រោយស្តីពីការបង្ការការឆ្លងមេរោគអេដស៍ | CDHS | ៣២.៧% | | ៣៤% CDHS |
| ៨ | ភាគរយនៃយុវវ័យដែលជាក្មេងស្រីអាយុ២០-២៤ឆ្នាំ ដែលមានចំណេះដឹងគ្រប់ជ្រុងជ្រោយស្តីពីការបង្ការការឆ្លងមេរោគអេដស៍ | CDHS | ៤២.៤% | | ៤៤% CDHS |
| ៩ | ភាគរយនៃយុវវ័យដែលជាក្មេងប្រុសអាយុ១៥-១៩ឆ្នាំ មានចំណេះដឹងគ្រប់ជ្រុងជ្រោយស្តីពីការបង្ការការឆ្លងមេរោគអេដស៍ | CDHS | ៤២.៤% | | ៤៤% CDHS |
| ១០ | ភាគរយនៃយុវវ័យដែលជាក្មេងប្រុសអាយុ ២០-២៤ឆ្នាំ ដែលមានចំណេះដឹងគ្រប់ជ្រុងជ្រោយស្តីពីការបង្ការការឆ្លងមេរោគអេដស៍ | CDHS | ៤៩.៩% | | ៥២% CDHS |
| ១១ | ភាគរយនៃស្ត្រីវ័យក្មេងអាយុ១៥-១៩ឆ្នាំបានធ្វើការរំលូតកូននៅមូលដ្ឋានសុខាភិបាល | HIS | NA | | |

| ល.រ | សូចនាករ | ប្រភព | ទិន្នន័យដើមគ្រា២០១៤ | ផែនការឆ្នាំ ២០១៨ | ផែនការឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ១២ | ភាគរយនៃស្ត្រីវ័យក្មេងអាយុ២០-២៤ឆ្នាំបានធ្វើការរំលូតកូននៅមូលដ្ឋានសុខាភិបាល | HIS | NA | | |
| ១៣ | ភាគរយនៃមន្ទីរពេទ្យបង្អែកដែលមានបុគ្គលិកបានទទួលការបណ្តុះបណ្តាលស្តីពីសុខភាពបន្តពូជយុវវ័យ | NRHP | NA | | |
| ១៤ | ភាគរយនៃមណ្ឌលសុខភាពដែលមានបុគ្គលិកបានទទួលការបណ្តុះបណ្តាលស្តីពីសុខភាពបន្តពូជយុវវ័យ | NRHP | NA | | |
| ១៥ | ភាគរយនៃមូលដ្ឋានសុខាភិបាលដែលបានផ្តល់សេវាយុវវ័យប្រកបដោយមិត្តភាព | NRHP | NA | | |
| ១៦ | ភាគរយនៃម្តាយវ័យក្មេងអាយុ១៥-១៩ឆ្នាំដែលបានពិនិត្យផ្ទៃពោះលើកទី៤ដោយបុគ្គលិកដែលមានជំនាញ | HIS CDHS | NA | | |
| ១៧ | ភាគរយនៃម្តាយវ័យក្មេងអាយុ២០-២៤ឆ្នាំដែលបានពិនិត្យផ្ទៃពោះលើកទី៤ដោយបុគ្គលិកដែលមានជំនាញ | HIS CDHS | NA | | |
| ១៨ | ភាគរយនៃម្តាយវ័យក្មេងអាយុ១៥-១៩ឆ្នាំដែលបានសម្រាលកូនដោយបុគ្គលិកដែលមានជំនាញ | HIS, CDHS | NA | | |
| ១៩ | ភាគរយនៃម្តាយវ័យក្មេងអាយុ២០-២៤ឆ្នាំដែលបានសម្រាលកូនដោយបុគ្គលិកដែលមានជំនាញ | HIS, CDHS | NA | | |
| ២០ | ភាគរយនៃយុវវ័យអាយុ១៥-១៩ឆ្នាំដែលមានភាពស្លេកស្លាំង | CDHS HIS | ៤៩.៤% CDHS | ៤៧% HIS | ៤៥% CDHS |
| ២១ | ភាគរយនៃយុវវ័យអាយុ២០-២៤ឆ្នាំដែលមានភាពស្លេកស្លាំង | HIS | NA | | |
| ២២ | ចំនួនយុវវ័យទទួលការថែទាំក្រោយការរំលោភបំពានផ្លូវភេទ | NRHP | NA | | |

# ១០. ការស្រាវជ្រាវ

## ១. ត្រូវធ្វើការស្រាវជ្រាវច្រើនទៀតអំពីការប្រព្រឹត្តិផ្លូវភេទរបស់យុវវ័យដូចជា៖

- សម្ពាធពីមិត្តភ័ក្តិ
- ការប្រព្រឹត្តរបស់បុរសមានផលប៉ះពាល់យ៉ាងដូចម្តេចទៅលើ អំពើហឹង្សា យេនឌ័រ
- ការប្រើប្រាស់សេវាពន្យារកំណើត
- ការមានផ្ទៃពោះមិនចង់បាន និងការរំលូតកូន
- អង្កេតប្រជាសាស្ត្រនិងសុខភាពពីដើម្បីឱ្យយល់ដឹងអំពីអាកប្បកិរិយានៃការស្វែងរកសេវាសុខភាពរបស់បុរស និងស្ត្រីវ័យក្មេង
- ការសិក្សាស្រាវជ្រាវក្នុងតំបន់គ្របដណ្តប់មូលដ្ឋានសុខាភិបាល
- ការប្រព្រឹត្តផ្លូវភេទរបស់យុវវ័យ ដូចជាក្មេងប្រុស ក្មេងស្រី ក្នុងសាលា ក្រៅសាលា
- ផ្សេងៗ

## ២. ការស្រាវជ្រាវត្រូវធ្វើទៅលើការផ្តល់សេវាដែលទាក់ទងទៅនឹងបញ្ហាដូចខាងក្រោម៖

- ចំណេះដឹង អត្តចរិក ការអនុវត្តន៍របស់អ្នកផ្តល់សេវាមាតាបិតា និងអ្នកដឹកនាំតាម ស្ថាប័ននានាដែលពាក់ព័ន្ធទៅនឹងសុខភាពបន្តពូជ និងសុខភាពផ្លូវភេទសម្រាប់យុវវ័យ
- ប្រសិទ្ធិផល និងប្រសិទ្ធភាពនៃសេវាសុខភាពបន្តពូជយុវវ័យ
- យុទ្ធសាស្ត្រ និងកម្មវិធីដែលមាន អំពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទរបស់ក្រុម គោលដៅចំណុចដូចជាម្តាយវ័យក្មេង និងកូនរបស់ពួកគាត់ កុមារកំព្រាដោយសារជំងឺអេដស៍ និងជនរងគ្រោះដោយសារអំពើហិង្សា មនុស្សដែលប្រឈមមុខទាំងផ្លូវកាយ និងផ្លូវចិត្ត

## ៣.ការស្រាវជ្រាវត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិក្រមសីលធម៌សម្រាប់ការស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស។

# ១១. ឧបសម្ព័ន្ធ

ក. បញ្ជីផ្ទៀងផ្ទាត់សម្រាប់បង្កើតកម្មវិធី

ខ. បញ្ជីសំនួរសម្រាប់ជ្រើសរើសមិត្តអប់រំមិត្ត

គ. បញ្ជីផ្ទៀងផ្ទាត់សម្រាប់វាយតម្លៃមូលដ្ឋានសុខាភិបាលដែលបានផ្តល់សេវាដល់យុវវ័យ (ដែលត្រូវទៅតាមលក្ខខណ្ឌ)

ឃ. តារាងរបាយការណ៍ប្រចាំខែស្តីពីការពិគ្រោះពិភាក្សាសម្រាប់យុវវ័យ (ព័ត៌មានទូទៅ)

ង. តារាងសរុបប្រចាំខែសម្រាប់ការពិគ្រោះពិភាក្សាជាមួយយុវវ័យ (ប្រធានបទ)

ច. តារាងចុះបញ្ជីប្រើប្រាស់រថយន្តសង្គ្រោះបន្ទាន់

១. សម្រាប់មណ្ឌលសុខភាព
២. សម្រាប់មន្ទីរពេទ្យបង្អែក

ឆ. ប័ណ្ណបញ្ជូន

១. ប័ណ្ណបញ្ជូនពីមណ្ឌលសុខភាព
២. ប័ណ្ណផ្តល់ដំណឹងពីការបញ្ជូនទៅមន្ទីរពេទ្យបង្អែក
៣. ប័ណ្ណបញ្ជូនរវាងមន្ទីរពេទ្យ និងមន្ទីរពេទ្យ

ជ. សំណួរសម្រាប់សម្ភាសន៍អតិថិជនពេលចេញពីកន្លែងទទួលសេវា (មិនទាន់មានឯកសារ)

ឈ. ឧបសម្ព័ន្ធសម្រាប់គ្រូបណ្តុះបណ្តាល

## ក. បញ្ជីផ្ទៀងផ្ទាត់សម្រាប់បង្កើតកម្មវិធី

| សូចនាករ | លក្ខខណ្ឌតម្រូវ | បាទ/ចាស | ទេ | មតិយោបល់ |
|---|---|---|---|---|
| វាយតម្លៃដើមគ្រានិងធ្វើឡើងសម្រាប់កំណត់ពីបញ្ហាសុខភាព បន្តពូជយុវវ័យ តម្រូវការនិងក្រុមគោលដៅ | ១.តើមានការវាយតម្លៃដើម្បីកំណត់បញ្ហាសុខភាពបន្តពូជនិងតម្រូវការរបស់យុវវ័យដែរឬទេ? | | | |
| | ២. តើមានការវាយតម្លៃដើម្បីកំណត់ពីក្រុមខុសគ្នារបស់ យុវវ័យដែរឬទេ? | | | |
| | ៣. តើមានការវាយតម្លៃដើម្បីកំណត់ពីកត្តាប្រឈម និង ការការពាររបស់យុវវ័យដែរឬទេ? | | | |
| | ៤. តើមានការវាយតម្លៃដើម្បីកំណត់បរិបទនៃឥរិយាបថប្រឈមនិងឥរិយាបថក្នុងការទៅរកសេវាសុខភាពក្នុងចំណោមយុវវ័យដែរឬទេ? | | | |
| វិភាគលើលទ្ធភាពដែលអាចធ្វើបាននៃ គោលនយោបាយ | ១. តើមានការវាយតម្លៃលើការគាំទ្ររបស់អ្នកពាក់ព័ន្ធជាមួយយុវវ័យដែរឬទេ? | | | |
| | ២. តើមានការពិនិត្យមើលឡើងវិញលើគោលនយោបាយនិងបទបញ្ញត្តការងារដែលអាចប៉ះពាល់ ដល់ការអនុវត្តកម្មវិធីសុខភាពបន្តពូជយុវវ័យ ដែរឬទេ? | | | |
| | ៣. តើមានការវាយតម្លៃលើការរៀបចំកិច្ចសហការជាមួយនឹងកម្មវិធីនិងសកម្មភាពសុខភាពបន្តពូជយុវវ័យដទៃទៀតដែរឬទេ? | | | |
| យុទ្ធសាស្ត្រនិងគោលដៅនៃកិច្ចអន្តរាគមន៍ដោយផ្អែកលើគំរូសកម្មភាពដែលនាំឱ្យមានការផ្លាស់ប្តូរឥរិយាបថរបស់យុវវ័យ | តើអ្នកបានបង្កើតគំរូសកម្មភាពដែលមានទំនាក់ទំនងរវាងប្រវត្តិកម្មវិធីសកម្មភាពនិងលទ្ធផលដែលសម្រេចបានដែរឬទេ? | | | |
| អ្នកពាក់ព័ន្ធនៅក្នុងតំបន់គ្របដណ្តប់ដែលបានចូលរួមក្នុងការធ្វើផែនការរបស់កម្មវិធី | ១. តើក្រុមយុវវ័យត្រូវបានចូលរួមក្នុងការធ្វើផែនការរបស់កម្មវិធីដែរឬទេ? | | | |
| | ២. តើបុគ្គលិកបំរើការងារក្នុងសាលារៀនរួមមានផ្នែកគ្រប់គ្រងគ្រូបង្រៀនបានចូលរួមក្នុងការធ្វើផែនការរបស់កម្មវិធីដែរឬទេ? | | | |
| | ៣. តើអាណាព្យាបាល ឪពុកម្តាយ បងប្អូនបានចូលរួមក្នុងការធ្វើផែនការរបស់កម្មវិធីដែរឬទេ? | | | |

| សូចនាករ | លក្ខខណ្ឌតម្រូវ | បាទ/ចាស | ទេ | មតិយោបល់ |
|---|---|---|---|---|
| | ៤. តើអ្នកបង្កើតគោលនយោបាយថ្នាក់ដឹកនាំខេត្តស្រុក ឃុំ ភូមិ បានចូលរួមក្នុងការធ្វើផែនការរបស់កម្មវិធីដែរឬទេ? | | | |
| | ៥. តើតំណាងក្រុមការងារសង្គមផ្សេងៗបានចូលរួមក្នុងការធ្វើផែនការរបស់កម្មវិធីដែរឬទេ? | | | |
| | ៦. តើអ្នកផ្តល់សេវាសុខភាព សេវាសង្គមបានចូលរួមក្នុងការធ្វើផែនការរបស់កម្មវិធីដែរឬទេ? | | | |
| ផែនការដែលមានស្រាប់សម្រាប់កៀរគរសហគមន៍ | ១. តើផែនការដែលមានស្រាប់នោះបានបញ្ចូលនិងជ្រើសរើសអ្នកពាក់ព័ន្ធនិងអ្នកដឹកនាំសហគមន៍ឱ្យមានការចូលរួមក្នុងការអនុវត្តសកម្មភាពរបស់កម្មវិធីដែរឬទេ? | | | |
| | ២. តើផែនការដែលមានស្រាប់នោះបានបង្កើតគណកម្មការសម្របសម្រួលដើម្បីជួយគាំទ្រសកម្មភាពសេវាសុខភាពបន្តពូជយុវវ័យដែរឬទេ? | | | |
| | ៣. តើផែនការដែលមានស្រាប់នោះបានដាក់បញ្ចូលនូវសារនិងព័ត៌មានស្តីអំពីសុខភាពបន្តពូជយុវវ័យ ទៅក្នុងកាលវិភាគនៃការអនុវត្តសកម្មភាពសហគមន៍ដែរឬទេ? | | | |
| វាយតម្លៃពីតម្រូវការរបស់បុគ្គលិកនិងទាមទារឱ្យមានវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ | ១. តើបានធ្វើការប៉ាន់ប្រមាណពីចំនួនបុគ្គលិកដែលមានឬទេ? | | | |
| | ២. តើការវាយតម្លៃបានបញ្ចូលពីប្រវត្តិបណ្តុះបណ្តាលរបស់បុគ្គលិកដែរឬទេ? | | | |
| | ៣. តើបានធ្វើការប៉ាន់ប្រមាណពីចំនួនបុគ្គលិកដែលមានសមត្ថភាពនិងទំនុកចិត្តក្នុងការធ្វើការជាមួយយុវវ័យដែរឬទេ? | | | |
| | ៤. តើបានធ្វើការប៉ាន់ប្រមាណពីចំនួនបុគ្គលិកដែលមានចំណេះដឹង ទាក់ទងទៅនឹងសុខភាពបន្តពូជយុវវ័យដែរឬទេ? | | | |
| | ៥. តើតម្រូវការបណ្តុះបណ្តាលនាពេលអនាគតនិងលក្ខខណ្ឌជ្រើសរើសត្រូវបានបង្កើតឡើងដែរឬទេ? | | | |
| វិភាគលើលទ្ធភាពដែលអាចប្រើប្រាស់បាននៃថវិកា | ១. តើមានការប៉ាន់ប្រមាណអំពីតម្រូវការថវិកាក្នុងកម្មវិធីដែរឬទេ? | | | |
| | ២. តើលទ្ធភាពនៃការបង់ប្រាក់និងការស្ម័គ្រចិត្តរបស់យុវវ័យក្នុងការបង់សេវាត្រូវបានវាយតម្លៃដែរឬទេ? | | | |
| | ៣. តើមានពិនិត្យមើលលើប្រភពគាំទ្រថវិកាដែរឬទេ? | | | |

## ខ. បញ្ជីសំនួរសម្រាប់ជ្រើសរើសមិត្តអប់រំមិត្ត

| បញ្ជីសំនួរសម្រាប់ជ្រើសរើសមិត្តអប់រំមិត្ត | | | | |
|---|---|---|---|---|
| ល.រ | លក្ខខណ្ឌជ្រើសរើស | ចាស/បាទ | ទេ | មតិយោបល់ |
| | **សំនួរសម្រាប់សហគមន៍** | | | |
| ១ | តើបេក្ខជនជាអ្នកដែលចេះគោរពគ្នាទៅវិញទៅមកដែរឬទេ? | | | |
| ២ | តើបេក្ខជនអាចរក្សាការសម្ងាត់បានដែរឬទេ? | | | |
| ៣ | តើបេក្ខជនមានទំនាក់ទំនងល្អជាមួយក្រុមយុវវ័យនិងមនុស្សពេញវ័យដែរឬទេ? | | | |
| ៤ | តើបេក្ខជនជាមនុស្សស្មោះត្រង់ យកចិត្តទុកដាក់នឹងការងារដែរឬទេ? | | | |
| | **សំនួរសម្រាប់បេក្ខជន** | | | |
| ៥ | តើអ្នកមានបំណងធ្វើឱ្យសុខភាពបន្តពូជនៅសហគមន៍បានល្អដែរឬទេ? | | | |
| ៦ | តើអ្នកចេះអាននិងសរសេរអក្សរដែរឬទេ? | | | |
| ៧ | តើអ្នកមានចំណេះដឹងផ្នែកសុខភាពបន្តពូជនិងផ្លូវភេទយុវវ័យដែរឬទេ? | | | |
| ៨ | តើអ្នកអាចយល់ពីស្ថានភាព និងធ្វើការអប់រំនៅទីសាធារណៈបានដែរឬទេ? | | | |
| ៩ | តើអ្នកអាចយល់ដឹងពីស្ថានភាពរបស់យុវវ័យដែលជាក្រុមគោលដៅដែរឬទេ? | | | |
| ១០ | តើបុគ្គលនេះមានអាយុឬវ័យប្រហាក់ប្រហែលនឹង យុវវ័យដែលជាក្រុមគោលដៅដែរឬទេ? (តាមការសង្កេត) | | | |

តើបេក្ខជននេះមានលក្ខខណ្ឌប៉ុន្មានភាគរយ? _____

តើបេក្ខជននេះគួរត្រូវបានជ្រើសរើសដែរឬទេ? □ ចាស □ ទេ

បញ្ជាក់៖ ក្នុងករណីដែលបេក្ខជនត្រូវតាមលក្ខខណ្ឌចាប់ពី ៨០% នៃកម្រងសំនួរខាងលើអាចត្រូវបានជ្រើសរើស។

## គ. បញ្ជីផ្ទៀងផ្ទាត់សម្រាប់វាយតម្លៃមូលដ្ឋានសុខាភិបាលដែលបានផ្តល់សេវាដល់យុវវ័យ (ដែលត្រូវទៅតាមលក្ខខណ្ឌ)

### សេចក្តីណែនាំ

បញ្ជីផ្ទៀងផ្ទាត់នេះត្រូវបានយកទៅប្រើមុនពេលធ្វើការណែនាំតម្រង់ទិសនិងក្រោយអនុវត្តការដាក់ពិន្ទុនិងកំណត់នូវស្ថានភាពមូលដ្ឋានសុខាភិបាលដែលទទួលស្គាល់ថាជាកន្លែងដែលផ្តល់សេវាសុខភាពយុវវ័យ

ការដាក់ពិន្ទុនៃសមាសធាតុចំបងនិងសមាសធាតុគាំទ្រត្រូវបានអនុវត្តដូចខាងក្រោម ៖

លេខ២៖ ប្រសិនបើត្រូវទៅតាមលក្ខខណ្ឌទាំងស្រុង

លេខ១៖ ប្រសិនបើត្រូវទៅតាមលក្ខខណ្ឌពាក់កណ្តាលឬសកម្មភាពកំពុងរៀបចំដំណើរការ

លេខ០៖ ប្រសិនបើមិនត្រូវទៅតាមលក្ខខណ្ឌ

ការកំណត់នូវស្ថានភាពមូលដ្ឋានសុខាភិបាលដែលទទួលស្គាល់ថាជាកន្លែងដែលផ្តល់សេវាយុវវ័យត្រូវបានគណនាដូចខាងក្រោម៖

- ៨០-១០០% នៃពិន្ទុសរុប៖ បានទទួលស្គាល់និងផ្តល់ស្លាកសញ្ញា
- ៦០-៧៩% នៃពិន្ទុសរុប៖ បានទទួលស្គាល់ប៉ុន្តែមិនទាន់ផ្តល់ស្លាកសញ្ញា និងត្រូវការពង្រឹងបន្ថែម
- ក្រោម៦០% នៃពិន្ទុសរុប៖ ត្រូវពង្រឹងបន្ថែមដើម្បីឱ្យត្រូវទៅតាមលក្ខខណ្ឌ

| ល.រ | សមាសធាតុចំបង | សកម្មភាព | ពិន្ទុ ២,១,០ | យោបល់/អនុសាសន៍ |
|---|---|---|---|---|
| ១ | ធានាភាពជាឯកជន | ត្រូវធានាថាបន្ទប់ពិគ្រោះយោបល់និងផ្តល់សេវាត្រូវបានរក្សាការសម្ងាត់ជូនយុវវ័យ និងមិនមានការរំខាន | | |
| ២ | បុគ្គលិកជំនាញ | អ្នកផ្តល់សេវាមានទំនាក់ទំនងល្អជាមួយយុវវ័យ ផ្តល់នូវសេវាសុខភាពបន្តពូជប្រកបដោយជំនាញ ពិភាក្សាអំពីជម្រើសក្នុងការបង្ការ(រួមមានការបង្ការទ្វេដង) និងអាចឆ្លើយនូវសំនួររបស់យុវវ័យបាន | | |
| ៣ | ការគោរពអត្តិថិជនដែលជាយុវវ័យ | បុគ្គលិកសុខាភិបាល (អ្នកទទួលភ្ញៀវ អ្នកផ្តល់ប្រឹក្សា អ្នកផ្តល់សេវា) ផ្តល់សេវាដល់យុវវ័យដោយការគោរពគួរសម និងផ្តល់ឱកាសឱ្យពួកគេសួរសំនួរ | | |
| ៤ | កញ្ចប់សេវាអប្បបរមា | សេវាដែលត្រូវបានផ្តល់ឱ្យយុវវ័យនៅតាមមូលដ្ឋានសុខាភិបាលមានដូចជា៖<br>• ពិគ្រោះពិភាក្សាពីអនាម័យនិងថែទាំសុខភាពបឋម<br>• ពិគ្រោះពិភាក្សាមុនពេលរៀបអាពាហ៍ពិពាហ៍និងការរួមភេទប្រកបដោយសុវត្ថិភាព<br>• ពន្យារកំណើត (រួមទាំងស្រោមអនាម័យ) និងការពារកំណើតបន្ទាន់ | | |

| ល.រ | សមាសធាតុចំបង | សកម្មភាព | ពិន្ទុ ២,១,០ | យោបល់/អនុសាសន៍ |
|---|---|---|---|---|
| | | • ពិគ្រោះពិភាក្សាអំពីមេរោគអេដស៍(បញ្ជូនសម្រាប់ការធ្វើតេស្តឈាមនិងថែទាំ)និងពិនិត្យព្យាបាលជំងឺកាមរោគ<br>• ការថែទាំពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាល (រួមមានតេស្តពិនិត្យរកមើលការមានផ្ទៃពោះ)<br>• ពិគ្រោះពិភាក្សានិងព្យាបាលក្រោយរងនូវអំពើហិង្សាផ្លូវភេទនិងការរំលោភបំពាន (បញ្ជូនទៅរកសេវាដែលពាក់ព័ន្ធ)<br>• ពិគ្រោះពិភាក្សានិងផ្តល់សេវាមុននិងក្រោយពេលរំលូតកូននិងពន្យារកំណើតបន្ទាប់ពីរំលូតកូន (រួមជាមួយការបញ្ជូនសម្រាប់ការគ្រប់គ្រងនូវផលវិបាកប្រសិនបើចាំបាច់)<br>• ពិគ្រោះពិភាក្សា អាហារូបត្ថម្ភ និងព្យាបាល ភាពស្លេកស្លាំង<br>• ពិគ្រោះពិភាក្សាពីការការពារជំងឺមហារីកមាត់ស្បូន ចំពោះស្ត្រីវ័យក្មេង(ចាក់ថ្នាំបង្ការក្មេងស្រីអាយុពី៩-១៣ឆ្នាំ) និងដោះ<br>កញ្ចប់សេវាទាំងនេះ អាចមានភាពខុសគ្នាទៅតាមកម្រិតមូលដ្ឋានសុខាភិបាលដែលត្រូវបានកំណត់ដោយក្រសួងសុខាភិបាល | | |
| ៥ | ការផ្គត់ផ្គង់សម្ភារ បរិក្ខារ និងឱសថ | សម្ភារ បរិក្ខារ និងឱសថត្រូវមានគ្រប់គ្រាន់នៅនឹងមូលដ្ឋានសុខាភិបាល និងមិនហួសកាលកំណត់ | | |
| ៦ | ការផ្តល់មធ្យោបាយ ពន្យារកំណើត | មធ្យោបាយពន្យារកំណើតត្រូវបានផ្តល់ឱ្យមានដូចជា៖ ស្រោមអនាម័យ ថ្នាំលេប ថ្នាំចាក់ កងដាក់ក្រោមស្បែក កងដាក់ក្នុងស្បូននិងមធ្យោបាយការពារកំណើតបន្ទាន់ | | |
| ៧ | ការប្រើប្រាស់ស្រោមអនាម័យ | ត្រូវពន្យល់គ្រប់អតិថិជនដោយមិនគិតពីស្ថានភាពគ្រួសារថា ស្រោមអនាម័យមានភាពងាយស្រួលក្នុងការស្វែងរក និងប្រើប្រាស់សម្រាប់ការពារការមានផ្ទៃពោះ និងកាមរោគ/អេដស៍ | | |
| ៨ | ការប្រើប្រាស់ ស្រោមអនាម័យបុក ជាមួយមធ្យោបាយពន្យារកំណើតមួយផ្សេងទៀត | ត្រូវពន្យល់ទៅកាន់ក្រុមយុវវ័យដែលប្រឈមមុខខ្ពស់ឱ្យប្រើប្រាស់ស្រោមអនាម័យបុកជាមួយមធ្យោបាយពន្យារកំណើតមួយផ្សេងទៀតដើម្បីការពារទាំងការមានផ្ទៃពោះនិងកាមរោគ/អេដស៍ឱ្យកាន់តែមានប្រសិទ្ធភាព | | |
| ៩ | ប្រព័ន្ធបញ្ជូន | ប្រព័ន្ធបញ្ជូនត្រូវមាននៅនឹងកន្លែងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់យុវវ័យ រួមមានបញ្ជូននៅពេលមានការរំលោភបំពានផ្លូវភេទ ការព្យាបាលការរងនូវអំពើហិង្សា ការថែទាំក្រោយរំលូត (ព្យាបាលផលវិបាក) និងការពិគ្រោះពិភាក្សាធ្វើតេស្តឈាមរកមេរោគអេដស៍។ល។ | | |
| ១០ | ការរក្សាការសម្ងាត់ | អ្នកផ្តល់សេវាធានារក្សានូវការសម្ងាត់របស់អតិថិជនទាំងការពិគ្រោះពិភាក្សា និងឯកសារពិនិត្យសុខភាព | | |
| ១១ | ពេលវេលារង់ចាំ | ពេលមកដល់មូលដ្ឋានសុខាភិបាល យុវវ័យត្រូវទទួលបាននូវសេវាមិនគួរលើសពី១ម៉ោងសម្រាប់ការរង់ចាំ។ ករណីមានការបញ្ជូនក្នុងបរិវេណមូលដ្ឋានសុខាភិបាលត្រូវធ្វើឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន | | |

| ល.រ | សមាសធាតុចំបង | សកម្មភាព | ពិន្ទុ ២,១,០ | យោបល់/ អនុសាសន៍ |
|---|---|---|---|---|
| ១៣ | តម្លៃសេវា | ផ្តល់សេវាដោយមិនគិតថ្លៃសម្រាប់យុវវ័យ ឬគិតថ្លៃក្នុងកម្រិតណាមួយសមស្របដែលមិនបណ្តាលឱ្យមានជាឧបសគ្គក្នុង ការទៅទទួលសេវា | | |
| ១៤ | ទីកន្លែង ឬ ពេលវេលា | កន្លែងរង់ចាំនិងបន្ទប់ពិគ្រោះពិភាក្សាគួរដាក់ដាច់ដោយឡែកពីអតិថិជនដទៃ ឬការផ្តល់សេវាយុវវ័យត្រូវបានផ្តល់នៅពេលវេលាពិសេស ដាច់ដោយឡែក ដែលអាចបង្កើនការរក្សាការសម្ងាត់ឱ្យកាន់តែប្រសើរ | | |
| សមាសធាតុគាំទ្រ | | | | |
| ១៥ | យោបល់/ព័ត៌មានត្រឡប់របស់យុវវ័យ | យុវវ័យត្រូវបានចូលរួមក្នុងការរៀបចំបង្កើតសេវាសម្រាប់យុវវ័យ ឬត្រូវមានយន្តការសម្រាប់យុវវ័យប្រើប្រាស់ក្នុងការផ្តល់ព័ត៌មានត្រលប់ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវា (តាមរយៈការប្រជុំ ការសម្ភាសន៍ អតិថិជន ...) | | |
| ១៦ | ទីតាំងផ្តល់សេវា | មូលដ្ឋានសុខាភិបាលត្រូវមានទីតាំងផ្តល់សេវាដែលមានភាពងាយស្រួលដល់យុវវ័យមកទទួលសេវា | | |
| ១៧ | ការផ្សព្វផ្សាយសេវាយុវវ័យ | អ្នកផ្តល់សេវាធ្វើការផ្សព្វផ្សាយពីសេវាសុខភាពយុវវ័យតាមរយៈការចុះអប់រំនៅមូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ ស្លាកសញ្ញានានា | | |
| ១៨ | បន្ទប់ផ្តល់សេវា | ការរៀបចំបន្ទប់ផ្តល់សេវាយុវវ័យត្រូវមាន សម្ភារដែលធ្វើឱ្យយុវវ័យមានភាពងាយស្រួលនិងទាក់ទាញ ដូចជាផ្ទាំងរូបភាពសម្រាប់យុវវ័យ ដោយមិនរៀបរាប់តែអំពីវេជ្ជសាស្ត្រ | | |
| ១៩ | មិត្តអប់រំមិត្ត/អ្នកផ្តល់សេវា | មិត្តអប់រំមិត្តឬអ្នកផ្តល់សេវាធ្វើការពិគ្រោះពិភាក្សាជាមួយ យុវវ័យនិងអប់រំនៅតាមមូលដ្ឋាន | | |
| ២០ | សម្ភារសម្រាប់ការអប់រំ | ខិត្តប័ណ្ណ សៀវភៅបិទបើក ផ្ទាំងរូបភាព...ស្តីពីប្រធានបទសំខាន់ៗ (ការបង្ការជំងឺកាមរោគ ការប្រើប្រាស់ស្រោមអនាម័យ...) ត្រូវមានសម្រាប់ប្រើប្រាស់នៅនឹងកន្លែងនិងយកទៅផ្ទះបាន | | |
| ២១ | ការនាំដៃគូមកពិនិត្យព្យាបាល | អ្នកផ្តល់សេវាលើកទឹកចិត្តយុវវ័យឱ្យនាំដៃគូមកទទួលការពិនិត្យនិងព្យាបាលរួមទាំងតម្រូវការរបស់គាត់ | | |
| ២២ | បុគ្គលិកដែលមិនមែនជាអ្នកផ្តល់សេវាយុវវ័យ | ត្រូវធ្វើការណែនាំដល់បុគ្គលិកដែលមិនមែនជាអ្នកផ្តល់សេវា ដូចជាអ្នកទទួលភ្ញៀវ សន្តិសុខ អ្នកសម្អាត... ឱ្យមានទំនាក់ទំនងល្អជាមួយយុវវ័យជាលក្ខណៈមិត្តភាព | | |
| ២៣ | ការអប់រំបន្ថែម | អ្នកផ្តល់សេវាគួរផ្តល់ការអប់រំបន្ថែមដល់ក្រុមយុវវ័យស្តីពីសុខភាពបន្តពូជ តាមរយៈការពិភាក្សាជាក្រុម ព្រឹត្តិការណ៍ពិសេស ។ល។ | | |
| ២៤ | ការអប់រំតាមមូលដ្ឋាន | នៅក្រៅមូលដ្ឋានសុខាភិបាលដូចជា សាលា សហគមន៍ មណ្ឌលសំចត (ប្រសិនបើមាន) មានការអប់រំតាមរយៈមិត្តអប់រំមិត្ត និងក្រុមទ្រទ្រង់សុខភាពភូមិ ដែលអាចផ្សារភ្ជាប់ និងបញ្ជូនយុវវ័យមកកាន់មូលដ្ឋានសុខាភិបាល ។ | | |

## ឃ. តារាងរបាយការណ៍ការពិគ្រោះពិភាក្សាសម្រាប់យុវវ័យ

| ស្ថានភាព | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក្រុមអាយុ | ក្រោម១៥ឆ្នាំ | | | | | | | | | | | | | |
| | ១៥-១៩ | | | | | | | | | | | | | |
| | ២០-២៤ | | | | | | | | | | | | | |
| ភេទ | ស្រី | | | | | | | | | | | | | |
| | ប្រុស | | | | | | | | | | | | | |
| ការអប់រំ | មិនបានសិក្សា | | | | | | | | | | | | | |
| | បឋមសិក្សា | | | | | | | | | | | | | |
| | អនុវិទ្យាល័យ | | | | | | | | | | | | | |
| | វិទ្យាល័យ | | | | | | | | | | | | | |
| | មហាវិទ្យាល័យ | | | | | | | | | | | | | |
| ស្ថានភាពគ្រួសារ | នៅលីវ | | | | | | | | | | | | | |
| | រៀបការ | | | | | | | | | | | | | |
| | មានដៃគូតែ មិនបានរៀបការ | | | | | | | | | | | | | |
| | លែងលះ/រស់នៅបែកគ្នា | | | | | | | | | | | | | |
| ស្ថានភាពភាពលំនៅដ្ឋាន | ជនបទ | | | | | | | | | | | | | |
| | ទីក្រុង/ ទីរួម ខេត្ត | | | | | | | | | | | | | |
| ស្ថានភាពងាយរងគ្រោះ | រស់នៅតាម ដងផ្លូវ | | | | | | | | | | | | | |
| | ស្ត្រីធ្វើការនៅកន្លែងសេវាកំសាន្ត | | | | | | | | | | | | | |
| | អ្នកប្រើប្រាស់ គ្រឿងញៀនឬគ្រឿង ស្រវឹង | | | | | | | | | | | | | |
| | ក្មេងក្រៅ សាលា | | | | | | | | | | | | | |
| | ផ្សេងៗ | | | | | | | | | | | | | |
| ស្ថានភាពការងារ | មិនមានការ ងារធ្វើ | | | | | | | | | | | | | |
| | កម្មករ/កម្មកា រិនី | | | | | | | | | | | | | |
| | សិស្ស/និស្សិត | | | | | | | | | | | | | |
| | ជាងសំណង់ | | | | | | | | | | | | | |
| | បុគ្គលិករដ្ឋ | | | | | | | | | | | | | |
| | បុគ្គលិកក្រុមហ៊ុន/អង្គការ | | | | | | | | | | | | | |
| | ផ្សេងៗ | | | | | | | | | | | | | |

## ង. តារាងសរុបប្រចាំខែសម្រាប់ការពិគ្រោះពិភាក្សាជាមួយយុវវ័យ (ប្រធានបទ)

ខែ................................

ឈ្មោះអ្នកផ្ដល់សេវា..................................

| | ចំនួនវគ្គនៃការពិគ្រោះពិភាក្សាជាបុគ្គល/ជាដៃគូ(ក) | ចំនួនវគ្គនៃការពិគ្រោះពិភាក្សាជាក្រុម(ខ) | ចំនួនយុវវ័យសរុបដែលបានចូលរួមវគ្គពិគ្រោះពិភាក្សា | ចំនួនសរុបវគ្គនៃការពិគ្រោះពិភាក្សា (ក)+(ខ) |
|---|---|---|---|---|
| អនាម័យនិងថែទាំសុខភាពបឋម | | | | |
| ពិគ្រោះពិភាក្សាមុនពេលរៀបអាពាហ៍ពិពាហ៍និងការរួមភេទប្រកបដោយសុវត្ថិភាព | | | | |
| ពន្យារកំណើត (រួមទាំងស្រោមអនាម័យ) និងការពារកំណើតបន្ទាន់ | | | | |
| (បញ្ជូនសម្រាប់ការធ្វើតេស្តឈាមនិងថែទាំ)និងពិនិត្យព្យាបាលជំងឺកាមរោគ | | | | |
| ការថែទាំពេលមានផ្ទៃពោះ ពេលសម្រាលនិងក្រោយសម្រាល (រួមមានតេស្តពិនិត្យរកមើលការមានផ្ទៃពោះ) | | | | |
| ក្រោយរងនូវអំពើហិង្សាផ្លូវភេទនិងការរំលោភបំពាន (បញ្ជូនទៅរកសេវាដែលពាក់ព័ន្ធ) | | | | |
| មុននិងក្រោយពេលរំលូតកូននិងពន្យារកំណើតបន្ទាប់ពីរំលូតកូន (រួមជាមួយការបញ្ជូនសម្រាប់ការគ្រប់គ្រងនូវផលវិបាកប្រសិនបើចាំបាច់) | | | | |
| អាហារូបត្ថម្ភ និងព្យាបាលភាពស្លេកស្លាំង | | | | |
| ការការពារជំងឺមហារីមាត់ស្បូន(ចំពោះស្ត្រីវ័យក្មេងអាយុពី៩-១៣ឆ្នាំ) | | | | |
| ពិគ្រោះពិភាក្សាសេវាសុខភាពផ្លូវចិត្ត | | | | |
| ផ្សេងៗ | | | | |
| សរុប | | | | |

## ច. តារាងចុះបញ្ជីប្រើប្រាស់រថយន្តសង្គ្រោះបន្ទាន់

**ឈ្មោះមណ្ឌលសុខភាព.......................................................**

| ល.រ | ថ្ងៃខែ | ពេលវេលា | ឈ្មោះអតិថិជន | អាយុ | ភេទ | ភូមិ | ឃុំ | ទីតាំងដែលទៅទទួល | រោគសញ្ញា | ទីតាំងដែលអតិថិជនទៅដល់ | ឈ្មោះបុគ្គលិកដែលជូនដំណើរ | ឈ្មោះអ្នកបើកបរ | ទឹកប្រាក់ដែលបានទទួល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

ជាតិ សាសនា ព្រះមហាក្សត្រ
ព្រះរាជាណាចក្រកម្ពុជា

**ខេត្ត៖.........................................**
**ស្រុកប្រតិបត្តិ៖...............................**
**មណ្ឌលសុខភាព៖..........................**
**លេខ៖.........................................**

## បណ្ណ័បញ្ជូនពីមណ្ឌលសុខភាព

ឈ្មោះអតិថិជន៖.................................... អាយុ៖................................ ភេទ៖.................................
អសយដ្ឋាន៖..........................................ភូមិ៖........................ឃុំ៖.......................ស្រុក៖........................
កាលបរិច្ឆេទបញ្ជូន៖..............................................ម៉ោង៖..............................................................................
កាលបរិច្ឆេទចូលមណ្ឌលសុខភាព៖...........................................................................................................

សញ្ញាគ្លីនិក៖

លទ្ធផលនៃការពិនិត្យ៖
សញ្ញាជីវិត៖ កំដៅ៖..................ជីពចរ៖..................សំពាធឈាម៖.............ចង្វាក់ដង្ហើម៖..................

ការព្យាបាលត្រូវបានផ្តល់នៅមណ្ឌលសុខភាព៖

ឱសថកំពុងព្យាបាល៖

ហេតុផលនៃការបញ្ជូន៖
ពិគ្រោះ ☐ សម្រាកពេទ្យ ☐

តួនាទីអ្នកបញ្ជូន៖ លេខទូរសព្ទអ្នកបញ្ជូន៖
ធ្វើនៅ ថ្ងៃ ខែ ឆ្នាំ
ហត្ថលេខា និងឈ្មោះ៖

ជាតិ សាសនា ព្រះមហាក្សត្រ
ព្រះរាជាណាចក្រកម្ពុជា

## ប័ណ្ណផ្តល់ដំណឹងពីការបញ្ជូនទៅមន្ទីរពេទ្យបង្អែក

មណ្ឌលសុខភាពដែលបញ្ជូនអតិថិជន៖

ឈ្មោះបុគ្គលិកមណ្ឌលសុខភាពដែលផ្តល់ព័ត៌មានក្នុងការបញ្ជូនទៅកាន់មន្ទីរពេទ្យ៖

ឈ្មោះអតិថិជន៖.................................... អាយុ៖.............................. ភេទ៖.................................. ....
អសយដ្ឋាន៖.........................................ភូមិ៖.......................ឃុំ៖.....................ស្រុក៖.......................
ថ្ងៃបញ្ជូន៖............................................ពេលវេលា៖................................................. .....................

សញ្ញាគ្រួញគ្រៃ៖

លទ្ធផលនៃការពិនិត្យ៖
សញ្ញាជីវិត៖ កំដៅ៖.................ជីពចរ៖.................សំពាធឈាម៖.............ចង្វាក់ដង្ហើម៖...................
សញ្ញាដទៃ៖

ការព្យាបាលដែលបានផ្តល់នាពេលបច្ចុប្បន្ន៖

រោគវិនិច្ឆ័យ៖

ប្រភេទនៃការធ្វើដំណើរ៖ ពេលវេលារំពឹងទុកដែលអតិថិជនមកដល់៖

ដំបូន្មានដែលផ្តល់ដោយមន្ទីរពេទ្យសម្រាប់ព្យាបាល/បញ្ជូន (និងដោយអ្នកណា)៖

តួនាទីអ្នកបញ្ជូន៖ លេខទូរសព្ទអ្នកបញ្ជូន៖

ធ្វើនៅ ថ្ងៃ ខែ ឆ្នាំ

ហត្ថលេខា និងឈ្មោះ៖

## តារាងចុះបញ្ជីប្រើប្រាស់រថយន្តសង្គ្រោះបន្ទាន់សម្រាប់មន្ទីរពេទ្យបង្អែក

ឈ្មោះមន្ទីរពេទ្យបង្អែក...........................................................

| ល.រ | ថ្ងៃខែ | ពេលវេលា | លេខគីឡូម៉ែត្រតំបូង | ឈ្មោះអតិថិជន | អាយុ | ភេទ | ភូមិ | ឃុំ | ទីតាំងដែលទៅទទួល | រោគសញ្ញា | ទីតាំងដែលអតិថិជនទៅដល់ | ឈ្មោះបុគ្គលិកដែលជូនដំណើរ | ឈ្មោះអ្នកបើកបរ | ទឹកប្រាក់ដែលបានទទួល | លេខគីឡូម៉ែត្រចុងក្រោយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |

ជាតិ សាសនា ព្រះមហាក្សត្រ
ព្រះរាជាណាចក្រកម្ពុជា

**ខេត្ត៖.......................................**
**ស្រុកប្រតិបត្តិ៖.............................**
**មណ្ឌលសុខភាព៖.........................**
**លេខ៖.......................................**

## បណ្ណ័បញ្ជូនរវាងមន្ទីរពេទ្យនិងមន្ទីរពេទ្យ

ឈ្មោះអតិថិជន៖..................................... អាយុ៖................................. ភេទ៖....................................
អស័យដ្ឋាន៖..........................................ភូមិ៖.......................ឃុំ៖.....................ស្រុក៖.......................
ថ្ងៃបញ្ជូន៖.............................................ពេលវេលា៖...........................................................................
ថ្ងៃចូលមន្ទីរពេទ្យ៖....................................................................................................................

ប្រវត្តិនៃការឈ្លញផ្ទៃរ៖

លទ្ធផលនៃការពិនិត្យ៖
សញ្ញាជីវិត៖ កំដៅ៖.................ជីពចរ៖.................សំពាធឈាម៖.............ចង្វាក់ដង្ហើម៖..................

ការព្យាបាលត្រូវបានផ្តល់នាពេលបច្ចុប្បន្ន៖

រោគវិនិច្ឆ័យ
ឱសថកំពុងប្រើប្រាស់៖

ហេតុផលនៃការបញ្ជូន៖

តួនាទីអ្នកបញ្ជូន៖ លេខទូរសព្ទអ្នកបញ្ជូន៖

ធ្វើនៅ ថ្ងៃ ខែ ឆ្នាំ
ហត្ថលេខា និងឈ្មោះ៖

# ១២. ឧបសម្ព័ន្ធសម្រាប់គ្រូបណ្តុះបណ្តាល

## ដើម្បីធ្វើឱ្យសមភាពនៃសេវាសុខភាពនៅកន្លែងផ្តល់សេវាមានភាពកាន់តែប្រសើរឡើង

### ១. គោលនយោបាយនិងទម្រង់ការនានាមាននៅនឹងកន្លែងនឹងធានាមិនឱ្យមានការកម្រិតអ្វីឡើយ ចំពោះការផ្តល់សេវាសុខភាព

#### (១) តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

មិនមានច្បាប់ និងគោលនយោបាយទាំងឡាយណាដែលកម្រិតដល់ការផ្តល់សេវាសុខភាពទៅតាមអាយុ ភេទ ឬប្រការផ្សេងៗទៀតឡើយ។

#### ហេតុអ្វីបានជាចំនុចមានសារៈសំខាន់?

នៅក្នុងប្រទេសជាច្រើន ដោយសារតែកត្តាច្បាប់ និងគោលនយោបាយមួយចំនួនដែលកំពុងតែអនុវត្តបានធ្វើឱ្យការផ្តល់សេវាសុខភាពទៅដល់ក្រុមយុវវ័យមួយចំនួន ឬទាំងអស់ប្រព្រឹត្តទៅដោយគ្មានការអនុញ្ញាតត្រឹមត្រូវឬដោយខុសច្បាប់។ កត្តាច្បាប់និងគោលនយោបាយដែលមានការដាក់កម្រិតទាំងនេះគឺជាឧបសគ្គដ៏ធំមួយក្នុងវិស័យសុខភាពសាធារណៈ។ ជាងនេះទៀតសោត កត្តាទាំងនេះគឺផ្ទុយទៅនឹងអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលចែងថា យុវជនមានសិទ្ធិរស់រានត្ត សិទ្ធិអភិវឌ្ឍ សិទ្ធិទទួលបានបទដ្ឋានសុខភាពខ្ពស់បំផុតតាមដែលអាចទទួលបាន និងសិទ្ធិទទួលបានការព្យាបាលជំងឺ និងស្តារនិតិសម្បទានៅតាមមូលដ្ឋានសុខាភិបាល (មាត្រា២៤)។

#### (២) តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

ត្រូវមាននីតិវិធីនានាដើម្បីធានាឱ្យបានថា មិនមានកត្តាណាឡើយ រួមមានអាយុ ភេទ ស្ថានភាពសង្គម សាវតារប្បធម៌ ដើមកំណើតជនជាតិ ពិការភាព ឬហេតុផលណាឯទៀតដែលអាច ៖

» រារាំងដល់ការផ្តល់សេវាសុខភាពទៅដល់ក្រុមយុវវ័យមួយចំនួន ឬទាំងអស់
» រារាំងដល់លទ្ធភាពរបស់ក្រុមយុវវ័យមួយចំនួនឬទាំងអស់ក្នុងការទទួលបាននូវសេវាសុខភាព

### ហេតុអ្វីបានជាចំនុចមានសារៈសំខាន់?

នីតិវិធីដែលកំពុងអនុវត្តនៅតាមបណ្តាប្រទេសមួយចំនួន គឺជាឧបសគ្គដែលរារាំងដល់ការផ្តល់ សេវាសុខភាព ហើយជាងនេះទៅទៀត គឺរារាំងមិនឱ្យយុវវ័យទទួលបាននូវសេវាថែទាំសុខភាពទៀត ផង។ យុវវ័យនឹងមិនទៅរកសេវាសុខភាពនៅតាមកន្លែងផ្តល់សេវាឡើយ បើសិនជាពួកគេគិតថាខ្លួនត្រូវបានគេរើសអើង។

## ២. អ្នកផ្តល់សេវាសុខភាពផ្តល់សេវាថែទាំព្យាបាលដល់យុវវ័យប្រកបដោយការយកចិត្តទុកដាក់និងការគោរពស្មើៗគ្នានិងមិនគិតអំពីស្ថានភាពអ្វីឡើយ

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

អ្នកផ្តល់សេវាសុខភាពផ្តល់សេវាព្យាបាល និងការយកចិត្តទុកដាក់ចំពោះយុវវ័យធ្វើឡើងនៅក្នុងកម្រិតដូចៗគ្នាដោយមិនគិតអំពីអាយុ ភេទ ស្ថានភាពសង្គម សាវតារវប្បធម៌ ដើមកំណើតជនជាតិ ពិការភាព ឬហេតុផលអ្វីឡើយ។

### ហេតុអ្វីបានជាចំនុចមានសារៈសំខាន់?

យុវវ័យនឹងមិនទៅស្វែងរកសេវាសុខភាពឡើយ បើសិនជាពួកគេមិនត្រូវបានគេផ្តល់តម្លៃនិងមិនមានការយកចិត្តទុកដាក់ពីអ្នកផ្តល់សេវាសុខភាព។ ការទទួលបានការគោរព និងការយកចិត្តទុកដាក់ស្មើៗគ្នាពីអ្នកផ្តល់សេវាសុខភាពបង្កឱ្យមានលទ្ធផលយ៉ាងល្អ ពោលគឺវាជួយជម្រុញលើកទឹកចិត្តឱ្យ យុវវ័យបន្តការណាត់ជួបរបស់ពួកគេនាពេលក្រោយៗទៀត ព្រមទាំងជួយណែនាំសេវាសុខភាពទាំងនោះទៅដល់មិត្តភក្តិរបស់ពួកគេផងដែរ។

## ៣. បុគ្គលិកជំនួយការផ្តល់សេវាថែទាំដល់យុវវ័យប្រកបដោយការយកចិត្តទុកដាក់និងការគោរពស្មើៗគ្នានិងមិនគិតអំពីស្ថានភាពអ្វីឡើយ

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

បុគ្គលិកជំនួយការផ្តល់សេវាសុខភាព និងការយកចិត្តទុកដាក់ចំពោះយុវវ័យធ្វើឡើងនៅក្នុងកម្រិតដូចៗគ្នាដោយមិនគិតអំពីអាយុ ភេទ ស្ថានភាពសង្គម សាវតារវប្បធម៌ ដើមកំណើតជនជាតិ ពិការភាព ឬហេតុផលអ្វីឡើយ។

### ហេតុអ្វីបានជាចំនុចមានសារៈសំខាន់ ?

យុវវ័យនឹងមិនទៅស្វែងរកសេវាសុខភាពឡើយ បើសិនជាពួកគេមិនត្រូវបានគេផ្តល់តម្លៃ និងមិនមានការយកចិត្តទុកដាក់ពីអ្នកផ្តល់សេវាសុខភាព។ ការទទួលបានការគោរព និងការយកចិត្តទុកដាក់ស្មើៗគ្នាពីអ្នកផ្តល់សេវាសុខភាពបង្កឱ្យមានលទ្ធផលយ៉ាងល្អ ពោលគឺវាជួយជម្រុញលើកទឹកចិត្តឱ្យ យុវវ័យបន្តការណាត់ជួបរបស់ពួកគេនាពេលក្រោយៗទៀត ព្រមទាំងជួយណែនាំសេវាសុខភាពទាំងនោះទៅដល់មិត្តភក្តិរបស់ពួកគេផងដែរ។

## ដើម្បីធ្វើឱ្យមធ្យោបាយទទួលបានសេវាសុខភាពនៅនឹងកន្លែងផ្តល់សេវាមានភាពកាន់តែប្រសើរឡើង

### ៤. មានគោលនយោបាយនិងនិតិវិធីនានាដែលធានាឱ្យមានការផ្តល់សេវាដែលឥតគិតថ្លៃឬក្នុងតម្លៃសមរម្យសម្រាប់យុវវ័យទាំងអស់

**តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?**

យុវវ័យទាំងអស់អាចទទួលបាននូវសេវាសុខភាពដោយឥតគិតថ្លៃ ឬក្នុងតម្លៃសមរម្យដែលអាចទទួលយកបាន។

**ហេតុអ្វីបានជាចំនុចមានសារៈសំខាន់ ?**

ចំណុចនេះផ្តោតជាពិសេសចំពោះយុវវ័យទាំងឡាយណាដែលមានជីវភាពគ្រួសារខ្វះខាត។ យុវវ័យដែលរស់នៅក្នុងក្រោមការទំនុកបម្រុងពីគ្រួសារ មិនចង់បន្ថែមបន្ទុកទៅដល់គ្រួសារដោយស្នើសុំប្រាក់មកចំណាយលើសេវាថែទាំសុខភាពឡើយ។ ហើយពួកគេអាចមានភាពស្ទាក់ស្ទើរក្នុងការបង្ហាញពីមូលហេតុដែលពួកគេត្រូវការសេវាសុខភាព។

### ៥. កន្លែងផ្តល់សេវាបើកដំណើរការក្នុងម៉ោងពេលដែលយុវវ័យអាចងាយស្រួលទៅជួបបានតើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

យុវវ័យអាចទៅរកសេវាសុខភាព នៅកន្លែងផ្តល់សេវា ក្នុងម៉ោងពេលថ្ងៃដែលពួកគេអាចទៅជួបបាន។

**ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់?**

យុវវ័យអាចមានការលំបាកក្នុងការទៅរកសេវា បើសិនជាកន្លែងផ្តល់សេវាបើកដំណើរការតែក្នុងម៉ោងដែលយុវវ័យមិនអាចទៅទទួលសេវាបាន ដូចជាត្រូវជាប់រវល់សិក្សា ធ្វើការងារ ឬធ្វើសកម្មភាព ផ្សេងៗទៀត។

### ៦. យុវវ័យយល់ដឹងអំពីអត្ថប្រយោជន៍ផ្សេងៗដែលយុវវ័យទទួលបានពីការស្វែងរកសេវាសុខភាពនិងដឹងពីមធ្យោបាយទៅស្វែងរកសេវាសុខភាពទាំងនោះ

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

យុវវ័យយល់ដឹងអំពីសេវាសុខភាពនានាដែលមានកន្លែងទទួលសេវា និងមធ្យោបាយទៅរកសេវាសុខភាពទាំងនោះ។

### ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់ ?

ការផ្តល់ព័ត៌មានអំពីសេវាសុខភាពនានាដែលមានទៅដល់យុវវ័យអាចជួយជម្រុញលើកទឹកចិត្តឱ្យពួកគេប្រើប្រាស់សេវាសុខភាពទាំងនោះ។

## ៧. ប្រជាជនក្នុងសហគមន៍យល់ដឹងអំពីអត្ថប្រយោជន៍ផ្សេងៗដែលយុវវ័យទទួលបានពីការស្វែងរកសេវាសុខភាពហើយពួកគេគាំទ្រដល់ការផ្តល់សេវាសុខភាពទាំងនោះទៅដល់យុវវ័យ

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

អាជ្ញាធរ ប្រជាជនក្នុងសហគមន៍ ដោយរួមទាំងឪពុកម្តាយផងដែរ យល់ដឹងអំពីអត្ថប្រយោជន៍ ផ្សេងៗនៃសេវាសុខភាពដែលអាចជួយដល់យុវវ័យក្នុងសហគមន៍របស់ពួកគេ។ ជាងនេះទៅទៀត ពួកគេជួយគាំទ្រទៅដល់ការផ្តល់សេវាសុខភាព និងជួយជម្រុញឱ្យយុវវ័យក្នុងសហគមន៍ប្រើប្រាស់សេវាសុខភាពទាំងនោះផងដែរ។

### ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់ ?

ប្រជាជនក្នុងសហគមន៍អាចនឹងប្រឆាំងទៅនឹងការផ្តល់សេវាសុខភាព ទៅកាន់ប្រជាជនវ័យជំទង់ បើសិនជាពួកគេមិនទាន់បានយល់ដឹងអំពីអត្ថប្រយោជន៍នៃសេវាសុខភាពឬមិនទុកចិត្ត។ ការបង្កឱ្យសហគមន៍បានចូលរួមក្នុងកិច្ចពិភាក្សា និងការធ្វើការពាក់ព័ន្ធទៅនឹងការផ្តល់សេវាសុខភាព ក្នុង សហគមន៍ មិនត្រឹមតែអាចជួយធ្វើឱ្យសកម្មភាពផ្តល់សេវាសុខភាពប្រព្រឹត្តទៅបានដោយគ្មានការតបតប្រឆាំងប៉ុណ្ណោះទេ តែអាចជួយធ្វើឱ្យយុវវ័យទទួលបានសេវាសុខភាពទាំងនោះផងដែរ។

## ៨. សេវាសុខភាពសម្ភារដែលពាក់ព័ន្ធនឹងសុខភាពត្រូវបានផ្តល់ទៅឱ្យយុវវ័យក្នុងសហគមន៍តាមរយៈសមាជិកសហគមន៍ដែលបានជ្រើសរើសអ្នកចុះធ្វើការតាមមូលដ្ឋាននិងយុវវ័យផ្ទាល់

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

សកម្មភាពនានាកំពុងតែដំណើរការនៅក្នុងសហគមន៍ ដើម្បីធ្វើយ៉ាងណាផ្តល់សេវាសុខភាពឱ្យបានជិតទៅនឹងកន្លែងដែលយុវវ័យរស់នៅ។ អ្នកចុះធ្វើការតាមមូលដ្ឋាន សមាជិកសហគមន៍ដែលបានជ្រើសរើសនិងយុវវ័យអាចចូលរួមក្នុងសកម្មភាពទាងនេះ អាស្រ័យទៅតាមស្ថានភាពទីកន្លែងជាក់ស្តែង

### ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់?

យុវវ័យមានភាពស្ទាក់ស្ទើរក្នុងការទៅស្វែងរកសេវានៅមូលដ្ឋានសុខាភិបាល ឬកន្លែងផ្តល់សេវានានា។ ជាងនេះទៅទៀត យុវវ័យខ្លះ ប្រហែលជាមិនអាចទៅស្វែងរកសេវាសុខភាពបាន។ ដូចនេះ សមាជិកសហគមន៍ដែលបានជ្រើសរើស អ្នកចុះធ្វើការតាមមូលដ្ឋាន និងយុវវ័យអាចពង្រីកបន្ថែមវិសាលភាពផ្តល់សេវាសុខភាពនៅក្នុងសហគមន៍។ យុវវ័យទំនងជាពេញចិត្តនិងគាំទ្រចំពោះការផ្តល់ព័ត៌មានអំពីសុខភាព និងការផ្តល់សេវាសុខភាពដោយមនុស្សក្នុងសហគមន៍ដែលពួកគេងាយស្រួលទៅជួប និងនៅតាមទីកន្លែងដែលងាយទៅ។

# ដើម្បីធ្វើឱ្យការទទួលបានសេវាសុខភាពនៅកន្លែងផ្តល់សេវាមានភាពកាន់តែប្រសើរឡើង

## ៩. មានគោលនយោបាយ និងនិតិវិធីដែលធានាដល់ការរក្សាការសម្ងាត់របស់អតិថិជន

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

គោលនយោបាយ និងនិតិវិធីនានាមាននៅនឹងកន្លែងផ្តល់សេវា ដើម្បីធានាដល់ការរក្សាការសម្ងាត់របស់យុវវ័យនៅគ្រប់ពេលទាំងអស់ លើកលែងតែតម្រូវដោយច្បាប់ឱ្យរាយការណ៍អំពីហេតុភេទនានាដូចជាការបៀតបៀនផ្លូវភេទ គ្រោះថ្នាក់ចរាចរណ៍ របួសដោយអាវុធ ទៅដល់អាជ្ញាធរពាក់ព័ន្ធ។

គោលនយោបាយ និងនិតិវិធីសម្រាប់៖

- **ការចុះឈ្មោះ៖** ព័ត៌មានអំពីអត្តសញ្ញាណផ្ទាល់ខ្លួនរបស់យុវវ័យ និងបញ្ហាដែលបង្ហាញត្រូវកត់ត្រានិងរក្សាទុកដោយសម្ងាត់
- **ការផ្តល់ប្រឹក្សា៖** ការរក្សាការសម្ងាត់ត្រូវធ្វើឡើងនៅគ្រប់ពេលទាំងអស់ដែលជួបជាមួយនឹងយុវវ័យ
- **ការកត់ត្រា៖** ករណីកំណត់ត្រានីមួយៗត្រូវរក្សាទុកនៅកន្លែងមានសុវត្ថិភាព និងដែលអាចទៅរកបានចំពោះតែបុគ្គលិកណាដែលមានការអនុញ្ញាតតែប៉ុណ្ណោះ
- **ការបង្ហាញព័ត៌មាន៖** បុគ្គលិកមិនត្រូវបង្ហាញព័ត៌មានណាដែលបានផ្តល់ដោយ ឬទទួលបានមកពីយុវវ័យ ទៅដល់បុគ្គលទី៣ (ឧ. សមាជិកគ្រួសារ គ្រូ ឬនយោជក...) ដោយគ្មានការយល់ព្រមជាមុនពីយុវវ័យឡើយ។

### ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់ ?

យុវវ័យមានភាពរសើបខ្លាំងទៅនឹងបញ្ហាឯកជន និងព័ត៌មានសម្ងាត់របស់ខ្លួន។ យុវវ័យនៅលើពិភពលោកនិយាយថា ពួកគេមានការព្រួយបារម្ភអំពីឯកជនភាព និងការរក្សាព័ត៌មានសម្ងាត់របស់ខ្លួនដែលជាហេតុធ្វើឱ្យពួកគេរុញរាមិនចង់ទៅស្វែងរក និងប្រើប្រាស់សេវាសុខភាព។

## ១០. កន្លែងផ្តល់សេវាសុខភាពធានាឯកជនភាព

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

កន្លែងផ្តល់សេវាសុខភាព ត្រូវមានទីតាំងនៅកន្លែងណាដែលជួយធានាដល់ឯកជនភាពរបស់យុវវ័យ។ នៅក្នុងកន្លែងនេះទៀតសោត ត្រូវមានបន្ទប់សមស្របដែលជួយធានាដល់ឯកជនភាពរបស់

យុវវ័យ។ នៅក្នុងគ្រប់ពេលដែលពួកគេទៅជួបអ្នកផ្តល់សេវា។ កន្លែងផ្តល់សេវានេះរួមមាន ផ្លូវចូល កន្លែងទទួលភ្ញៀវ កន្លែងរង់ចាំ កន្លែងពិនិត្យ និងកន្លែងរក្សាទុកព័ត៌មានកត់ត្រារបស់អតិថិជន។

### ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់?

យុវវ័យផ្តល់អាទិភាពខ្ពស់ចំពោះឯកជនភាពរបស់ពួកគេ។ ពួកគេភាគច្រើនទំនងជាទទួលបានសេវាសុខភាពដែលពួកត្រូវការបើសិនជាពួកគេមានទំនុកចិត្តថាព័ត៌មានផ្ទាល់ខ្លួនមិនត្រូវអ្នកដទៃឯទៀតមើល ហើយកំណត់ត្រាព័ត៌មានទាំងនោះត្រូវបានរក្សាទុកដោយសម្ងាត់។

## ១១. អ្នកផ្តល់សេវាសុខភាពមានការយកចិត្តទុកដាក់ រួសរាយរាក់ទាក់ចំពោះយុវវ័យ និងមិនធ្វើការវិនិច្ឆ័យរិះគន់លើពួកគេឡើយ

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

អ្នកផ្តល់សេវាថែទាំសុខភាព មិនរិះគន់ដល់អ្នកជំងឺវ័យជំទង់របស់ខ្លួន បើទោះបីជាអ្នកផ្តល់សេវាមិនពេញចិត្តនឹងពាក្យសម្តី ឬសកម្មភាពរបស់យុវវ័យក៏ដោយ។ ពួកគេត្រូវយកចិត្តទុកដាក់ដល់អ្នកជំងឺ និងទទួលស្វាគមន៍ប្រកបដោយឥរិយាបថរួសរាយរាក់ទាក់។

### ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់ ?

អ្នកផ្តល់សេវាថែទាំសុខភាព មិនចាំបាច់បោះបង់ចោលនូវជំនឿ និងគុណតម្លៃផ្ទាល់ខ្លួនរបស់ពួកគេនោះទេ ប៉ុន្តែពួកគេត្រូវធានាឱ្យបានថា ជំនឿ និងតម្លៃទាំងនោះមិនបានជះឥទ្ធិពលអវិជ្ជមានទៅលើរបៀបដែលពួកគេផ្តល់សេវាទៅដល់អ្នកជំងឺវ័យជំទង់ឡើយ ។ លើសពីនេះទៀត ការមានសមត្ថភាពក្នុងការឆ្លើយតបប្រកបដោយការយល់ចិត្តទៅកាន់យុវវ័យ នឹងរួមចំណែកដ៏សំខាន់ដល់ការបង្កឱ្យមានទំនាក់ទំនងគ្នាល្អ និងការគោរពគ្នាទៅវិញទៅមក។

ការមានឥរិយាបថវិនិច្ឆ័យរិះគន់ មិនយកចិត្តទុកដាក់ និងមិនរួសរាយរាក់ទាក់ចំពោះយុវវ័យធ្វើឱ្យរាំងស្ទះដល់ទំនាក់ទំនងល្អជាមួយពួកគេ ហើយជាងនេះទៀតសោត វាអាចធ្វើឱ្យពួកគេគេចវេះមិនទៅរកសេវាសុខភាពផងដែរ។

## ១២. ការរង់ចាំទទួលយកការផ្តល់ប្រឹក្សានៅកន្លែងផ្តល់សេវាមានរយៈពេលខ្លីសមល្មមទោះបីមានការណាត់ជួបជាមុនឬមិនមានក៏ដោយហើយត្រូវបញ្ជូនបន្តភ្លាមៗទៅរកសេវាសុខភាពដែលមាននៅកន្លែងផ្សេងទៀត ក្នុងករណីចាំបាច់

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

យុវវ័យអាចជួបពិគ្រោះយោបល់ជាមួយអ្នកផ្ដល់សេវាថែទាំសុខភាព ដោយមិនចាំបាច់រង់ចាំយូរ ទោះពួកគេបានឬមិនបានធ្វើការណាត់ជួបអ្នកផ្ដល់សេវាជាមុនក៏ដោយ ហើយពួកគេគួរត្រូវបានបញ្ជូនបន្តភ្លាមៗទៅកន្លែងផ្ដល់សេវាដែលពួកគេត្រូវការក្នុងករណីដែលសេវាទាំងនោះមិនអាចរកបាននៅនឹងកន្លែង។

### ហេតុអ្វីបានជាចំនុចមានសារៈសំខាន់?

យុវវ័យទំនងជាមិនទៅរកសេវាសុខភាពនៅកន្លែងផ្ដល់សេវានោះទេ ប្រសិនជាពួកគេត្រូវចំណាយពេលរង់ចាំយូរ ឬត្រូវអនុវត្តតាមគោលនយោបាយសាំញ៉ាំនានា សម្រាប់ធ្វើការណាត់ជួបអ្នកផ្ដល់សេវា។ ការតម្រូវឱ្យពួកគេរង់ចាំយូរដើម្បីធ្វើការណាត់ជួបជាមុនជាមួយនឹងអ្នកផ្ដល់សេវា អាចបណ្ដាលឱ្យពួកគេពន្យារឬខកខានការណាត់ជួប ឬទៅស្វែងរកសេវាពីអ្នកផ្ដល់សេវាសុខភាពឯទៀត ដោយសារតែនៅទីនោះត្រូវចំណាយពេលរង់ចាំតិច។ កត្តានេះអាចនាំឱ្យពួកគេទទួលបានប្រសិទ្ធិភាពតិចតួច និងថែមទាំងអាចបង្កគ្រោះថ្នាក់ផ្សេងៗដល់សុខភាពរបស់ខ្លួនទៀតផង ។

## ១៣. កន្លែងផ្ដល់សេវាមានបរិស្ថានស្អាតនិងមានការស្វាគមន៍រួសរាយរាក់ទាក់

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

កន្លែងផ្ដល់សេវាសុខភាពផ្ដល់ការស្វាគមន៍រាក់ទាក់ មានភាពទាក់ទាញ និងមានបរិស្ថានស្អាត។

### ហេតុអ្វីបានជាចំនុចមានសារៈសំខាន់ ?

ដូចមនុស្សពេញវ័យដែរ យុវវ័យមិនទៅកន្លែងផ្ដល់សេវាសុខភាពណាដែលមិនមានបរិស្ថានស្អាត និងខ្វះអនាម័យនោះឡើយ។

## ១៤. កន្លែងផ្ដល់សេវាផ្ដល់ព័ត៌មានផ្នែកសុខភាពតាមមធ្យោបាយច្រើនប្រភេទ

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

សម្ភារព័ត៌មានដែលទាក់ទងទៅនឹងសុខភាពរបស់យុវវ័យ ត្រូវបានផ្ដល់នៅតាមបណ្ដាកន្លែងផ្ដល់សេវាសុខភាពក្នុងបែបផែនចម្រុះផ្សេងៗគ្នា (ឧ. ផ្ទាំងរូបភាព កូនសៀវភៅ និងខិតប័ណ្ណ) ។ សម្ភារទាំងនោះបានត្រូវបានផលិតឡើងដោយប្រើភាសាងាយស្រួលយល់ និងប្រកបដោយភាពទាក់ទាញ។

### ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់?

យុវវ័យដែលមកជួបជាមួយនឹងអ្នកផ្តល់សេវា អាចមិនយល់ដឹងអំពីបញ្ហាផ្សេងៗដែលអាចធ្វើឱ្យប៉ះពាល់ដល់ស្ថានភាពសុខភាពរបស់ពួកគេ។ ជាងនេះទៅទៀត ពួកគេអាចទទួលបានព័ត៌មានមិនត្រឹមត្រូវពីមិត្តភក្តិរបស់ពួកគេ ឬពីប្រភពផ្សេងៗទៀត។ ពួកគេប្រហែលជាមានមានសំណួរផ្សេងៗទាក់ទិនទៅនឹងសុខភាព ប៉ុន្តែពួកគេមានភាពខ្មាស់អៀន ក្នុងការសាកសួរឪពុកម្តាយរបស់ខ្លួន គ្រូ ឬអ្នកដទៃទៀត។

## ១៥. យុវវ័យចូលរួមយ៉ាងសកម្មក្នុងការងារវាយតម្លៃអំពីសេវាសុខភាព និងការផ្តល់សេវាសុខភាព

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

យុវវ័យត្រូវបានផ្តល់ឱកាសដើម្បីចូលរួមចែករំលែកបទពិសោធន៍របស់ពួកគេក្នុងការទទួលបានសេវាសុខភាពនិងដើម្បីបង្ហាញពីតម្រូវការ ក៏ដូចជាចំណង់ចំណូលចិត្តរបស់ពួកគេអំពីសេវាសុខភាព។ ក្នុងកាលៈទេសៈដែលសមស្របខ្លះ ពួកគេក៏ចូលរួមក្នុងការងារផ្តល់សេវាសុខភាពផងដែរ។

### ហេតុអ្វីបានជាចំនុចមានសារៈសំខាន់ ?

ការបង្កឱ្យយុវវ័យបានចូលរួមនៅក្នុងដំណើរការវាយតម្លៃលើការផ្តល់សេវាសុខភាព និងនៅក្នុងដំណើរការនៃការផ្តល់សេវាសុខភាពអាចជួយធ្វើឱ្យសេវាទាំងនោះមានលក្ខណៈកាន់តែសមស្រប និងកាន់តែមានភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ពួកគេ។

## ភាពសមស្របនៃសេវាសុខភាពសម្រាប់យុវវ័យអាចកើតឡើងបាន ប្រសិនជា៖

### ១៦. សេវាថែទាំសុខភាពដែលចាំបាច់ដើម្បីបំពេញនូវតម្រូវការរបស់យុវវ័យ ត្រូវបានផ្តល់ឱ្យនៅនឹងកន្លែងផ្តល់សេវា ឬតាមរយៈកន្លែងបញ្ជូនបន្តដែលពាក់ព័ន្ធគ្នា

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

តម្រូវការ និងបញ្ហាផ្នែកសុខភាពនានារបស់យុវវ័យទាំងអស់ ត្រូវបានឆ្លើយតប តាមរយៈការផ្តល់សេវាសុខភាពនៅនឹងកន្លែងផ្តល់សេវា ឬតាមរយៈកន្លែងបញ្ជូនបន្តផ្សេងៗទៀតដែលពាក់ព័ន្ធគ្នា។ សេវាសុខភាពដែលបានផ្តល់ឱ្យ មានលក្ខណៈសមស្របទៅតាមតម្រូវការជាក់លាក់របស់យុវវ័យដែលងាយរងគ្រោះ ឬក្រុមយុវវ័យភាគច្រើន។

### ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់ ?

យុវវ័យទាំងអស់គួរទទួលបានសេវាសុខភាពត្រឹមត្រូវតាមតម្រូវការរបស់ពួកគេ តាមរយៈកន្លែង ផ្តល់សេវាសុខភាព ឬតាមរយៈកន្លែងបញ្ជូនបន្តដែលពាក់ព័ន្ធគ្នា ប្រកបដោយការជួយជ្រោមជ្រែង។

## ប្រសិទ្ធភាពនៃសេវាសុខភាពសម្រាប់យុវវ័យអាចសម្រេចបាន ប្រសិនជា៖

### ១៧. អ្នកផ្តល់សេវាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាសុខភាព

**តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?**

អ្នកផ្តល់សេវាថែទាំសុខភាពមានចំណេះដឹង និងជំនាញគ្រប់គ្រាន់សម្រាប់ធ្វើការជាមួយនឹងក្មេងជំទង់ និងសម្រាប់ផ្តល់សេវាសុខភាពដែលត្រូវការ។

**ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់ ?**

អ្នកផ្តល់សេវាថែទាំសុខភាព ចាំបាច់ត្រូវមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញការងារ ទាំងនៅក្នុងការងារផ្តល់សេវាទៅដល់យុវវ័យទូទៅ និងការងារផ្តល់សេវាទៅដល់ " ក្រុមយុវវ័យជាក់លាក់ " ពាក់ព័ន្ធទៅនឹងការងារលើកកម្ពស់ផ្នែកសុខភាព ការផ្តល់សេវាបង្ការ ការផ្តល់សេវាព្យាបាល និងស្តារនិតិ សម្បទា ក៏ដូចជានៅក្នុងការងារទំនាក់ទំនងរវាងបុគ្គល និងការប្រាស័យទាក់ទងគ្នាផងដែរ ។

### ១៨. អ្នកផ្តល់សេវាសុខភាពប្រើប្រាស់ពិធីសារ និងការណែនាំផ្អែកតាមភស្តុតាងដើម្បីផ្តល់សេវាសុខភាពនានា

**តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?**

ការផ្តល់សេវាសុខាភិបាលត្រូវផ្អែកលើពិធីសារ និងគោលការណ៍ណែនាំនានាដែលមានលក្ខណៈបច្ចេកទេសត្រឹមត្រូវនិងប្រកបដោយអត្ថប្រយោជន៍។ ជាការប្រសើរ ពិធីសារ និងគោលការណ៍ណែនាំទាំងនោះត្រូវស្របទៅតាមល័ក្ខខ័ណ្ឌថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងត្រូវទទួលបានការអនុម័តដោយអាជ្ញាធរពាក់ព័ន្ធផងដែរ។

**ហេតុអ្វីបានជាចំនុចមានសារៈសំខាន់ ?**

តាមរយៈការប្រើប្រាស់ឧបករណ៍ទាំងនេះ អ្នកផ្តល់សេវាមានភាពប្រាកដច្បាស់ក្នុងការអនុវត្តកញ្ចប់សកម្មភាពប្រសើរបំផុតសម្រាប់ឆ្លើយតបទៅនឹងអ្នកជំងឺវ័យជំទង់របស់ខ្លួន។

## ១៩. អ្នកផ្តល់សេវាសុខភាពចំណាយពេលវេលាគ្រប់គ្រាន់ ប្រកបដោយប្រសិទ្ធភាព ដើម្បីធ្វើការជួបជាមួយនឹងយុវវ័យ

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

អ្នកផ្តល់សេវាថែទាំសុខភាពចំណាយពេលវេលាគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាព ក្នុងការជួបពិភាក្សាជាមួយយុវវ័យរបស់ខ្លួន។

### ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់ ?

កត្តានេះមានហេតុផលដ៏សំខាន់ចំបងចំនួនពីរៈ ទីមួយ យុវវ័យប្រហែលជាមានការពិបាកក្នុងការប្រាស្រ័យទាក់ទង ពួកគេអាចមានការខ្មាស់អៀន ឬភ័យខ្លាច ហើយអាចនឹងត្រូវការការលើកទឹកចិត្ត និងពេលវេលាបន្ថែមទៀត ដើម្បីនិយាយអំពីការព្រួយបារម្ភដ៏ពិតប្រាកដរបស់ពួកគេ។ ទីពីរ គឺដោយសារតែអ្នកផ្តល់សេវាថែទាំសុខភាពត្រូវការពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការជាមួយនឹងអ្នកជំងឺរបស់ពួកគេ ក្នុងគោលបំណងទទួលបានប្រសិទ្ធភាពពេញលេញ។

## ២០. កន្លែងផ្តល់សេវាសុខភាពមានសម្ភារ ឧបករណ៍ និងសេវាចាំបាច់ផ្សេងៗដើម្បីផ្តល់សេវាសុខភាព

### តើចំណុចនេះចង់បញ្ជាក់អំពីអ្វី?

កន្លែងផ្តល់សេវាសុខភាព មានឧបករណ៍ និងសម្ភារចាំបាច់ (រួមទាំងថ្នាំពេទ្យ) និងសេវាមូលដ្ឋាន (ឧ. ទឹក និងអនាម័យ) ដែលត្រូវការជាចាំបាច់សម្រាប់ធ្វើការផ្តល់សេវាសុខភាព។

### ហេតុអ្វីបានជាចំនុចនេះមានសារៈសំខាន់?

បើសិនជាមិនមានសម្ភារមូលដ្ឋានសម្រាប់យកមកប្រើប្រាស់ទេនោះ គេមិនអាចធ្វើការផ្តល់សេវាសុខភាពប្រកបដោយប្រសិទ្ធិភាពបានឡើយ។ ការផ្តល់សេវាសុខភាពក្នុងរបៀបនេះ អាចនឹងនាំឱ្យមានគ្រោះថ្នាក់ផ្សេងៗដល់សុខភាពរបស់យុវវ័យ។